# ប៉ាង ខាត់

# ល្បើកអង្គរវត្ត

១៥៤២ស័ក, គ.ស.១៦២០

LPOEK ANGKOR VATT
(Poème d'Angkor Vatt, 1542 Çaka, 1620 A.D.)

លំនាំដើម
ដោយ សុខា ទូន និង ហន ណាយណី

Editions Angkor
ព.ស ២៥៥៣   គ.ស ២០០៩
រោងពុម្ព ម៉េងហាវ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

## សេចក្តីថ្លែងអំណរគុណ និង កិច្ចឧទ្ទិស

១. យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះលោកស្រីសាស្ត្រាចារ្យ-បណ្ឌិត ពៅ សាវរស ដែលបានផ្តល់ឯកសារ និង ផ្តល់យោបល់សព្វប្រការ ។ រីឯការខ្វះខាត ខ្វោះខ្វះផ្សេងៗទៀត គឺជាការភ្លាំភ្លង ឬ កំហុសរបស់យើងខ្ញុំ ។

២. យើងខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនដល់វិញ្ញាណខ័ន្ធនៃលោកកវី-និពន្ធ បណ្ឌិតទាំងអស់ ដែលបានខិតខំបណ្តុះបណ្តាល ជ្រោង ស្ទួយ ពង្រាយ និង រក្សាអក្សរសាស្ត្រខ្មែរ ។

៣. សូមឧទ្ទិសជាពិសេសដល់កម្ពុជា ។

---

# លំនាំដើម

ដោយ សុខា ឆួម និង ហម ឆាយលី

## ១. ប្រវត្តិខ្លះនៃកំណាព្យខ្មែរ

តាមរយៈសីលាចារឹកដែលនៅសេសសល់ច្រើនជាងឯកសារដែលចារលើរបស់ផ្សេងៗ ដូចជាចារលើស្លឹករឹត ចារលើក្រដាសប៉ុយ (ក្រដាសផ្លត់ ឬក្រាំង) លើស្បែក លើផ្ទាំងថ្ម... ដែលអស់លោកអ្នកសិក្សាស្រាវជ្រាវបានរកឃើញនៅកម្ពុជា និងមានចុះកាលប្បវត្តិត្រឹមត្រូវ គេបានដឹងថាខ្មែរយើងមានចារតាំងតែពីសតវត្សទី៥មកម្ល៉េះ ។ គេឃើញមានសន្លឹកសន្ធាប់ ចារជាភាសាខ្មែរសម្រាយ ប៉ុន្តែ សិលាចារឹកឯទៀតជាច្រើនចារជាភាសាសំស្ក្រឹត និងជាកំណាព្យទៀតផង [១] ។ អញ្ចឹងហើយ ទើបគេឃើញកំណាព្យជាភាសាសំស្ក្រឹតប្រើប្រាស និងចាររហូតដល់ដើមស.វ.ទី១៤។ តាំងពីពេលនោះមក ខ្មែរយើងលែងប្រើភាសាសំស្ក្រឹតក្នុងការនិពន្ធផ្សេងៗទៀតហើយ ។ នៅពេលនោះហើយ (ស.វ.ទី១៤) ដែលពុទ្ធសាសនាផ្នែកថេរវាទ ត្រូវបាននាំចូលមកប្រទេសខ្មែរជំនួសព្រហ្មញ្ញសាសនាដែលខ្មែរជឿ និង គោរពចាប់តាំងពីដើមគ្រិស្តសករាជមកម្ល៉េះ [២] ។ រីឯព្រះពុទ្ធសាសនាផ្នែកថេរវាទបានប្រើភាសាបាលីជាយាន ។ ចំណែកពុទ្ធសាសនាផ្នែកមហាយាន គេនៅតែបន្តប្រើភាសាសំស្ក្រឹតរហូតមក (ឧ. ប្រទេសទីបេត៍, ប៊ូតាន់, ណេប៉ាល់...) ។

ចាប់ពីដើមស.វ.ទី១៤មក ខ្មែរយើងក៏ចាប់យកភាសាបាលីមកប្រើវិញ ក្នុងការនិពន្ធធម៌ និងអក្សរសាស្ត្រផ្សេងៗ [៣] សម្រាប់សូត្រគោរពព្រះពុទ្ធ ។ ដូច្នេះ ចាប់តាំងពីសម័យកណ្ដាលនៅកម្ពុជា, កវី គាត់និពន្ធកំណាព្យជាភាសាបាលីសម្រាប់សូត្រធម៌រំលឹកពុទ្ធសាសនា... [៤] ។ បន្តបន្ទាប់មក កវី-និពន្ធខ្មែរនៅសម័យកណ្ដាលចូលចិត្តនិពន្ធអក្សរសាស្ត្រផ្សេងៗ, និងប្រលោមលោកជាកំណាព្យជាភាសាជាតិខ្លួនទន្ទឹមនិងភាសាបាលីរហូតមកដល់បច្ចុប្បន្ននេះ ។ ឧទាហរណ៍ : រឿងរាមកេរ្តិ៍ (យើងពុំស្គាល់ឈ្មោះអ្នកនិពន្ធទេ), ស្នាដៃរបស់អ្នកកវី ចាំង តាត គឺល្បើកអង្គរ (សូមអានអត្ថនៅខាងក្រោមនេះ), ស្នាដៃរបស់អ្នកកវី ឧកញ៉ា ជ័យ ឧទ្ធ (សិលាចារឹកទំនើបអង្គរវត្ត ក. ៣៨) [៥]...។ និងរហូតមកទៀត ដល់សម័យខ្មែរទំនើបស.វ.ទី១៨-ទី២០នេះមានស្នាដៃរបស់

---

1. Voir Barth, Auguste, Inscription sanskrite du Cambodge, Imprimerie Nationale, Paris 1885 ; Pou, Saveros, «L'Epigraphie khmère» , Angkor et Dix Siècles d'Art khmer, Paris R.M.N., 1997 : 53-61.
2. [ពៅ សាវរស, ព្រះពុទ្ធសាសនាថេរវាទ, និពន្ធនៅខែកុម្ភៈ ព.ស.២៥៣៦, គ.ស.១៩៩៣ (ពុំបានចុះផ្សព្វផ្សាយទេ)] ។

"ព្រះបាទសម្តេច ហរិរក្សរាមា ឥស្សរាធិបតី អង្គ ឌួង" (ព្រះបរមកោដ្ឋ) : ច្បាប់ស្រី, ឯណាវ, ចំប៉ាថោង, កាកី...។ -ស្នាដៃរបស់លោកកវី "ភិរម្យភាសាអ៊ុក អ្វ ហៅង៉ុយ" [6] ...សុទ្ធសឹងតែនិពន្ធឡើងជាភាសាខ្មែរសម្រាយទាំងអស់ ។

## ២. ប្រវត្តិសង្ខេបនៃអ្នកកវី-និពន្ធ និង អ្នកសិក្សាស្រាវជ្រាវខ្លះដែលមានថ្វីដៃល្បីល្បាញ

នៅសតវត្ស ទី១០

### ២.១ ម្រតាញ ស្រីឥន្ទ្របណ្ឌិត និង ស្រីវាចយុត្ត, និពន្ធសិលាចារឹក "បាទ ជុំ" នៅឆ្នាំជាមួយគ្នា ៨៦៦ស័ក, គ.ស.៩៤៤ ។

នៅកម្ពុជានាសម័យមុនអង្គរក្តី នាសម័យអង្គរក្តី ព្រាហ្មណ៍ ឬកវីដែលសាងសិលាចារឹក គឺសាងតាមព្រះរាជបញ្ញត្តិរបស់ព្រះមហាក្សត្រិយ៍ ទោះបីថា អស់លោកទាំងនោះមានចំណេះ មានទេពកោសល្យខាងតាក់តែងចងក្រងនិពន្ធក៏ដោយ ។ ដូច្នេះហើយ ទើបគេជួបប្រទះដោយកម្រណាស់នូវសិលាចារឹកដែលមានចុះនាមរបស់គាត់ដែលជាអ្នកនិពន្ធនោះ ។ ប៉ុន្តែ គេបានស្រាវជ្រាវឃើញនៅក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ ដែលទ្រង់សោយរាជ្យនៅឯ "ក្រុងយសោធរបុរៈ", អង្គរធំ មានកវីពីរនាក់របស់ទ្រង់បាននិពន្ធសិលាចារឹកបាទ ជុំ គឺ :

១. ម្រតាញ "ស្រី ឥន្ទ្របណ្ឌិត" (ក. -ស្រី : ទ្រព្យដ៏ប្រសើរ, + ខ. -ឥន្ទ្របណ្ឌិត : ជាអ្នកប្រាជ្ញរបស់ព្រះឥន្ទ្រ, អ្នកដែលមានប្រាជ្ញដូចព្រះឥន្ទ្រ) ។

២. "ស្រី វាចយុត្ត" (ក. -ស្រី : ទ្រព្យដ៏ប្រសើរ, +ខ. -វាចយុត្ត : សម្តីដែលប្រសើរ សម្តីត្រឹមត្រូវ, ពាក្យត្រឹមត្រូវ) ។ ឧ. វាចសិក, យុត្តកិច្ច, យុត្តក្រិត្យ...(នាមទាំង

3. Coedès, George, Etudes cambodgiennes (XXXII)
« La plus ancienne inscription en Pāli du Cambodge », *BEFEO*, t. XXXVI, Fasc. I, 1936.
Pou, Saveros, « Sanskrit, Pāli and Khmero-Pāli in Cambodia », Panels of the VII th World Sanskrit Conference, Vol. VII, Sanskrit Outside India, (ed. J.G. de Casparis), Leiden..., Brill, 1991 : 13-28.

4. Filliozat, Jean, « Une inscription cambodgienne en Pāli et en khmère », de 1566 ( K.82 Vatt Nagar, Kompong Cham), *Acad. des Inscriptions et des Belles Lettres*, Janvier-Mars 1969 : 93...

5 Pou, Saveros, « Inscriptions Modernes d'Angkor Vat », K.38, *BEFEO*, t. LXII, 1975 : 293-353.

6. បណ្ណាំក្រម ង៉ុយ, បណ្ណាគារ សេង ងួនហួត, ភ្នំពេញ ឆ្នាំ១៩៦៤ ។



នេះ ជាប្រវត្តិជីវិតឆ្ងាយទន្ទឹមនិងប្រវត្តិកម្ពុជា និងបានស្ថាបនាប្រទេសកម្ពុជាទៀតផង) បានចុះនាមរបស់លោកពីក្រោមសិលាចារឹកដែលលោកបាននិពន្ធ នៅឆ្នាំជាមួយគ្នាគឺ ៨៦៦ស័ក, ត្រូវនឹង គ.ស. ៩៤៤ ។ ដូច្នេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវដឹងថា គាត់ទាំងពីរជាកវី-និពន្ធ របស់ព្រះមហាក្សត្រិយ៍ [7] សម័យនោះ ។

គួរកត់សំគាល់ដែរថា នៅសម័យគាត់ ជាមហាសាគរនៃព្រហ្មញ្ញសាសនា, គឺថា សាសនានេះកំពុងតែរីកស្គុះស្គាយ និងមានឥទ្ធិពលពេញព្រះរាជាណាចក្រ ។ កវីនិពន្ធទាំងពីរនេះ លោកបារជាសិលាចារឹករំលឹកដម្កើងព្រះពុទ្ធសាសនាផ្នែកមហាយាន ។ ឧទាហរណ៍ : ព្រះជិន្នៈ, ព្រះទិវយទេវី, ព្រះស្រីវជ្ជរាបាំណី, ព្រះជ័យន្តទេសៈ, ព្រះកុជីស្វរៈ...។ ប៉ុន្តែ អ្នកកវី-និពន្ធទាំងពីរ នេះលោកនៅតែចងចាំរំលឹកដម្កើងព្រះនានា ផ្នែកខាងព្រហ្មញ្ញសាសនាដ៏រាប គាត់ឥតបានបោះបង់ចោលសាសនាដើមរបស់គាត់ និងរបស់ប្រជារាស្ត្រខ្មែរឡើយ ។ ឧទាហរណ៍ : ព្រះឥស្វរៈ, ព្រះកៅរី (ព្រះឥស្វរ), ព្រះសារិង្គិន (ព្រះវិស្ណុ), ព្រះមឃវ័ន្ត (ព្រះឥន្ទ្រ), ព្រះសម្ភុ (ព្រះឥស្វរ) ...។ បានសេចក្តីថា : -ព្រះទាំងនេះស្ថិតនៅរស់រវើកចាក់ឫសយ៉ាងមាំរឹងជាប់ក្នុងអារម្មណ៍ និងក្នុងស្នាដៃនិពន្ធរបស់គាត់ជាដ៏រាប ។ ជាពិសេសទៅទៀត សហគមន៍ខ្មែរចេះរួមរស់នៅជាមួយគ្នាតាំងតែពីដើមគ្រិស្តសករាជម្ល៉េះ ទោះជាព្រះមហាក្សត្រិយ៍ទ្រង់ជឿលើ និងគោរពព្រហ្មញ្ញសាសនា, អ្នកប្រាជ្ញអក្សរសាស្ត្រ, កវី-បណ្ឌិត ដែលនៅជាបរិវារគាល់ហ្វៅ, ប្រជានុរាស្ត្ររបស់ទ្រង់ជឿគោរពសាសនាផ្សេងក៏ដោយ ដូចជា : មហាយាន, ព្រះវិស្ណុ, ព្រះឥស្វរក្តី គេឥតមានប្រកាន់ចាប់ទោសទាស់ទែង ទោម្នេញនិងគ្នាជាទំនាស់ "លទ្ធិនិយម" ឡើយ [ពៅ សាវរស, *បទានុក្រមសំស្ក្រឹតប្រើក្នុងភាសាខ្មែរ* ពុំទាន់បានចុះផ្សព្វផ្សាយនៅឡើយទេ] ។

នៅសតវត្ស ទី១៦

### ២.២ កវីអនាមិក និពន្ធរឿងរាមកេរ្តិ៍

បន្តមកដល់សម័យកណ្តាល (ស.វ.ទី១៥-១៨) មានស្នាដៃយ៉ាងប្រណីតមួយទៀតដែលខ្មែរយើងបានចងចាំស្ទើរតែរាល់រូបគឺ "រឿងរាមកេរ្តិ៍" ។

១. អំពីចម្លាក់ "រឿងរាមកេរ្តិ៍" ដែលព្រះមហាក្សត្រិយ៍អង្គរបានសាងឡើងក្នុងអំឡុង ស.វ.

7 Voir Coedès, George, « Inscription de Bat Chum », *Journal Asiatique*, t. XII, Septembre-Octobre 1908.

ទី១២ នោះ [៨] ការសាងចម្លាក់គឺ ពិតជាសាងតាមសេចក្ដីរឿងរ៉ាវដែលចងចាំតៗគ្នាមក តែអ្នកសិក្សាស្រាវជ្រាវ ជាពិសេសលោកស្រីបណ្ឌិត-សាស្ត្រាចារ្យ ពៅ សាវរស អ្នកប្រាជ្ញឯកទេស "រឿងរាមកេរ្តិ៍" ពុំបានរកឃើញចំណារដៃទេគឺ មានតែចម្លាក់ប៉ុណ្ណោះ ។ ទំនងដូចជាមានឯកសារចំណារដៃជាសាស្ត្រាស្លឹករឹត ឬ ក្រាំង តែត្រូវពុកផុយដោយធាតុសំណើម, ឬ ត្រូវខ្មោចខ្មាំងដោយសារស្នាដៃមនុស្ស? ។

២. បន្តក្រោយមកទៀត ទើបលោកស្រីបានរកឃើញចំណារដៃសរសេរ និងបានសិក្សាតាមវិធីវិទ្យាសាស្ត្រទំនើប ឃើញថាស្នាដៃនោះត្រូវកវីនិពន្ធឡើងក្នុងស.វ.ទី១៦ ឬ ទី១៧ គឺ "រឿងរាមកេរ្តិ៍ខ្មែរ" [៩] ។ ក៏ប៉ុន្តែ អ្នកសិក្សាស្រាវជ្រាវនៅតែពុំស្គាល់នាមនៃអ្នកកវីខ្មែរដែលជាអ្នកនិពន្ធនោះឡើយ ទោះបីគេដឹងថា "រឿងរាមកេរ្តិ៍ខ្មែរ" មានប្រភព និងកវីខ្មែរបានចេះចាំមកពីប្រទេស ភារត (ឥណ្ឌា) និងនាមរបស់អ្នកនិពន្ធឈ្មោះ "វាលមិកិ" ក៏ដោយ ។

**នៅសតវត្ស ទី១៧**

**២.៣ កវីអ្នក ប៉ាំង តាត និពន្ធល្បើកអង្គរវត្ត**

នៅមហាសករាជ ១៥៤២ស័ក, គ.ស.១៦២០ លោកបានបន្សល់ទុកស្នាដៃដ៏ប្រណីតមួយ គឺ "ល្បើកអង្គរវត្ត" ដែលខ្មែររាល់រូបបានចងចាំ ហើយទំនងជាតាមរយៈព្រះភិក្ខុសង្ឃគ្រប់ៗវត្តដែលព្រះអង្គមានភារៈកិច្ចបង្រៀនបន្តៗគ្នាមក ។ ដូចដែលយើងខ្ញុំនឹងបង្ហាញស្នាដៃនោះជាប្រធានធំ [១០] [ប៉ាំង តាត, (Pāṅ Tāt), Cf. Pou Saveros, Présentation de Lpoek Nagar Vatt, Octobre 2002, pages 10-11, l'oeuvre inédite.] ។

**២.៤ ឧកញ្ញាំយោមរាជជ័យ នន្ទ គាត់ទំនងជាអ្នកនិពន្ធសិលាចារឹកទំនើបអង្គរវត្ត ក. លេខ ៣៤, ក.៣៨, ។**

លុះ៨១ឆ្នាំញយកន្ទងមកទៀត ឧកញ៉ាយមរាជបានស្គាល់ស្នាដៃ និងចងចាំយ៉ាងច្បាស់ នូវស្នាដៃរបស់កវីប៉ាំង តាត ។ ដូចមានអត្ថបទបញ្ជាក់មួយវគ្គថា :

8 Voir Coedès, George, « La date d'Exécution des Bas-Reliefs tardifs d'Angkor Vat », *Journal Asiatique*, t. CCL, 1962 : 235-248.

9 Voir Pou, Saveros, *Etudes sur le Rāmakerti (XVIè - XVIIè Siècle), PEFEO*, Paris 1977 ;
- *Rāmakerti I, (XVIè - XVIIè Siècle),* Texte Khmer Publié par…, *PEFEO*, Paris 1979 ;
- *Rāmakerti II, (XVIè - XVIIè Siècle),* Texte Khmer Traduction et Annotation, *PEFEO*, Paris 1982.



*…"លែងជាតិនេះទៅ បើវិលមកនៅ កើតផ្ទៃស្ដេចហោង*
*បានដូចចៅកេត មាលាហោះផង ទៅសួគ៌ទាយហោង*
*ជាកូនព្រះឥន្ទ្រ* ។
*ហើយមកជាស្ដេច សាងនគរស្រេច នៅខាងគិរិន្ទ្រ*
*ព្រះពិស្ណុការ វិលឡើងទៅវិញ អ្នកកេតឯងមិញ*
*សោយរាជ្យនៅអាយ"…* ។

(ពៅ សាវរស, សិលាចារឹកទំនើបអង្គរវត្ត ក. ៣៤. ក.៣៨, វគ្គទី ១៣៨ ដល់ ១៣៩, *BEFEO.*, t. LXII, Paris 1975 : 340) ។

លោកស្រី ពៅ សាវរសបានធ្វើការស្រាវជ្រាវរកឃើញស្នាដៃទាំងពីរនេះ : ក.៣៤… ដែលនិពន្ធឡើង នៅមហាសករាជ ១៦២៣ស័ក, គ.ស.១៧០១ ជាស្នាដៃល្អឯកនាសម័យកណ្ដាលនៃកម្ពុជា ដែលមានអត្ថាធិប្បាយជីវប្រវត្តិ និងសកម្មភាពរបស់ឧត្តមមន្ត្រី នៃព្រះមហាក្សត្រិយ៍ព្រះបាទជ័យជេដ្ឋាទី៣ [១១] ។

ស្នាដៃរបស់លោកជ័យ នន្ទមួយទៀតមានឈ្មោះថា "សាស្ត្រាក្បាម" ។ ជាស្នាដៃដែលមានឧត្តមគតិប្រពៃណាស់ សម្រាប់ជាក្បួននៃដំណើរជីវិតប្រចាំថ្ងៃ គឺបំណងរបស់គាត់ចង់ណែនាំដល់កុលបុត្របៀនប្រដៅខ្មែរឲ្យមានការប្រុងប្រយ័ត្ន ត្រូវរៀបចំខ្លួន ប្រុងប្រៀប រៀបចំការពារគ្រួសារឲ្យបានពីចម្ងាយ មិនឲ្យខ្មែរធ្វេសប្រហែសក្នុងជីវិត មិនឲ្យមើលងាយដល់សត្រូវឡើយ ទោះជាបណ្ដាំនៃប្រទេសជាតិក្ដី… ទើបបានចាកផុតពីទុក្ខភ័យ [១២] ពីព្រោះ ជីវិតតែងតែប្រទះខ្មាំងប្រទះឧបស័គ្គ, សត្រូវ, ឧក្រិដ្ឋកម្មសព្វប្រការ, ប្រទះកលយុគផ្សេងៗ ពុំដែលស្ងប់ ឬគេចផុតឡើយ…។ ក្រោយបំផុត គាត់បានឡើងឋានន្តរស័ក្តិជាបន្តបន្ទាប់ : ឧកញ្ញាំ សុរិន្ទ្រាធិរាជ, ចៅហ្វាបាំងក្ស័ប្វន…។

**នៅសតវត្ស ទី១៩-២០**

10. Aymonier, Etienne, « Lpoeuk Nokor Vatt », Imprimé à Saïgon, 1878 : 265-295.

11. V. Pou, Saveros, « Inscriptions Modernes d'Angkor Vat », (IMA 34- 38), *BEFEO.*, t. LXII, Paris 1975 : 293…

វង់ សុធារ៉ា, សិលាចារឹក សម័យកណ្ដាលនៃកម្ពុជា នឹងនៅ បោះពុម្ពផ្សាយ នៅអនាគតឆាប់ៗនេះ ។

២.៥ ព្រះបាទសម្តេច ព្រះហរិរក្សរាមា ឥស្សរាធិបតី អង្គ ឌួង (កំណើត គ.ស.១៧៩៦, សោយរាជ្យពី គ.ស.១៨៤៥ ដល់ គ.ស.១៨៦០, បច្ឆាមរណនាម : ព្រះបរមកោដ្ឋ) ។

ទ្រង់បាននិពន្ធច្បាប់ស្រី, ឯណាវ, ចំប៉ាថោង, កាកី (និពន្ធនៅគ.ស.១៨១៥) [13] ទ្រង់ស្រឡាញ់អក្សរសាស្ត្រជាតិ ទ្រង់ជាកវីដ៏ល្បីល្បាញ ។

២.៦ ព្រះបទមបារមី ពេជ្ជ, ឋានន្តរស័ក្តិជាមេគណនៅខេត្តបាភ្នំ (ឆ្នាំកំណើត?, ឆ្នាំសុគត?)

ព្រះអង្គបាននិពន្ធ :

១. សាស្ត្រាវត្តក្រូច (ស្រុកព្រៃឈរ ខេត្តកំពង់ចាម) ។

២. សាស្ត្រាល្បើករបាក្សត្រផែន្ទី និងទេយរាជា អង្គ ច័ន្ទ ។

ទោះបីយើងខ្ញុំខ្វះខាតច្រើនអំពីប្រវត្តិរបស់ព្រះបទមបារមីពេជ្ជ (មេគណនៅខេត្តបាភ្នំ) ក៏ដោយ ក៏យើងខ្ញុំត្រូវតែរំលឹកខ្លះអំពីស្នាព្រះហស្តរបស់ព្រះអង្គ ។ ព្រោះជាកវី-និពន្ធមួយអង្គ ដ៏ជំនាញ ប៉ុន្តែ សាធារណៈជនខ្មែរពុំសូវស្គាល់ស្នាព្រះហស្តរបស់ព្រះអង្គឡើយ ។ ស្នាព្រះហស្តរបស់ព្រះអង្គពីរ និពន្ធជាកំណាព្យទាំងអស់ ហើយជាពិសេសស្នាព្រះហស្តនេះ ទាក់ទងនិងសម័យកាលដែលកម្ពុជាយើងក្លាយជាលានប្រយុទ្ធ : -ម្ខាងជាមួយអាណ្ណាម ។ -ម្ខាងទៀតជាមួយសៀម នាស.វ.ទី១៨ និងដើមសវ.ទី១៩ ។ និងម្យ៉ាងទៀត អំពីព្រឹត្តិការណ៍ដែលមេទ័ពយួនកេណ្ឌប្រជារាស្ត្រខ្មែររាប់សែននាក់ឲ្យទៅជីកព្រែកវិញ តេ (ឬ ហៅថាព្រែកយួន) និងធ្វើទណ្ឌកម្មយ៉ាងព្រៃផ្សៃផង ។

-ស្នាព្រះហស្ត ទី១ "សាស្ត្រាវត្តក្រូច" ពុំបានដឹងថ្ងៃខែពិតដែលចារនិពន្ធនោះទេ តែព្រះគ្រូច័ន្ទ ជាចៅអធិការវត្តចុងកោះ ខេត្រកំពង់ចាម ជាអ្នកចារចម្លងឡើងវិញ នៅថ្ងៃព្រហស្បតិ៍ ទី២០ ខែមករា គ.ស.១៨៧៦ ។ ស្នាព្រះហស្តនោះនិពន្ធជាបទព្រហ្មគិត, ពំនោល, កាកគតិ, ភុជង្គលីលា ទាំងអស់មាន ១៤២៦វគ្គ ។

12 Pou, Saveros, Girlande de Cpāp', Edité par *Cedoreck.*, 1988 : 243-307.

13 កាកី និពន្ធនៅ ១៧៣៧ស័ក. គ.ស.១៨១៥ ។ Voir aussi Lamant, Pierre L., « La date de la mort du Roi Ang Duong», *BEFEO.*, t. LXIV, Paris 1977 : 217... ។



-ស្នាព្រះហស្ត ទី២ "សាស្ត្រាល្បើក របាក្សត្រផែន្ទី និងទេយរាជាអង្គ ច័ន្ទ" និពន្ធនៅ គ.ស. ១៨៥៥ ។ ស្នាព្រះហស្តនោះនិពន្ធជាបទព្រហ្មគិត, ពំនោល, កាកគតិ, ភុជង្គលីលា និងបន្ទោលកាកទាំងអស់មាន៥៨២វគ្គ (សូមអានឯកសារផម្តល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ)។

២.៧ ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ (គ.ស.១៨៥៩-១៩២៤)

ស្នាដៃ : -គតិលោក (មាន ១០ខ្សែ),

-និរាសអង្គរវត្ត (ជាពាក្យកាព្យ) និពន្ធនៅឆ្នាំ១៩០៥, អំបែងបែក (២ភាគ), ព្រះរាជពង្សាវតារ (ប្រែពីភាសា សៀម) ។

ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ ក្រោយពីបានសិក្សាជ្រៅជ្រះផ្នែកព្រះពុទ្ធសាសនា, ខាងធម៌អាថ៌, ភាសាបាលី និងភាសាជាតិយ៉ាងជំនាញ លោកបានសិក្សាបន្ថែមទាំងភាសាថៃផង ។ ដោយចំណេះចេះដឹងទាំងប៉ុន្មានរបស់គាត់នេះហើយ ទើបគាត់ខិតខំនិពន្ធចងក្រងជាច្បាប់ផ្សំ ជាក្បួនសីលធម៌ បែបវប្បធម៌ទុកឲ្យកុលបុត្រខ្មែរសិក្សា ។

-លោកបានចូលរួមជាមួយគណកម្មការ នៃការនិពន្ធចងក្រងវចនានុក្រមខ្មែរ ជាមួយសម្តេចព្រះសង្ឃរាជ ជួន ណាត ។

-ស្នាដៃរបស់លោកផ្សេងទៀតគឺ គតិធម៌ក្នុងលោក : បានសេចក្តីថា ជារឿងពិតដែលអ្នកប្រាជ្ញយើង លោកដកស្រង់ដើម្បីបំផុស និងបង្ហាញសម្រាប់បង្រៀនសីលធម៌ដល់សង្គមខ្មែរ [14] លោកបានបន្សល់ស្នាដៃដ៏ច្រើនទៀត។ លោកជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរម្នាក់យ៉ាងល្បីល្បាញ។

២.៨ ភិរម្យភាសា អ៊ុក អ៊ូ ហៅ ង៉ុយ (គ.ស.១៨៦៥-១៩៣៦)

លោកបាននិពន្ធ : ច្បាប់ក្រមង៉ុយ, ច្បាប់ល្បើកថ្មី ឬ ច្បាប់កេរ្តិ៍កាលថ្មី, សេចក្តីរំលឹកដាស់តឿន, ពាក្យកាព្យប្រដៅជនប្រុស-ស្រី [15] ។

14 ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ, ក. គតិលោក, មាន១០ខ្សែ, បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៧១ ។ ខ. និរាសនគរវត្ត (ជាពាក្យកាព្យ), បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស.១៩៦៨ ។ គ. អំបែងបែក (២ភាគ), បណ្ណាគារ ជីង ងួនហួត ភ្នំពេញ គ.ស.១៩៥៣ ។ ព្រះរាជពង្សាវតារ (ក្រាំងសរសេរដោយដៃផ្ទាល់) ប្រែជាភាសាបារាំង ដោយ ម៉ាកទីន ពីយ៉ាត (Cf. Piat, Martine, « Chronique Royal Khmer » (1595-1809), *BSEI.*, XLIX, Fasc.1, 1974 : 35-140 ; et *BSEI.*, XLIX, Fasc 4, Saïgon 1974.)

និពុកម្ដាយរបស់គាត់បានបញ្ជូនគាត់ឲ្យទៅសិក្សានៅវត្តអង្គបឹងចក នៅក្នុងស្រុកកំណើតរបស់គាត់ ។ លោក អ៊ុក អ៊ូ ជាអ្នកឧស្សាហ៍រៀនសូត្រណាស់ ។ បន្ទាប់មកគាត់បានបួសជាសាមណេរ បេះធម៌អាចារ្យយ៉ាងជ្រៅជ្រះ ។ លុះគម្រប់វ័យ២១វស្សា សាមណេរង៉ុយបានបំពេញសម្បទាជាភិក្ខុ ។ ភិក្ខុ ង៉ុយបានសិក្សាធម៌ព្រះត្រៃបិតកក្នុងសំណាក់ព្រះគ្រូអាចារ្យ "ទិត្យ" វត្តអង្គបឹងចក ភូមិបែកស្គរ ឃុំបែកបាន ស្រុកភ្នំពេញ ខេត្តកណ្ដាល ។ ក្រោយមកលោកបានចាកសិក្ខាបទមកជាគ្រហស្ថ ហើយបានរៀបអាពាហ៍ពិពាហ៍នៅភូមិស្រុករបស់លោក ។

ពីភូមិមួយទៅភូមិមួយបណ្ឌិត "ង៉ុយ" តែងតែច្រៀងកំណាព្យផ្សំជាមួយចាប៉ីខ្សែវៀវ (ដំបន់ខ្លះហៅ សាវៀវ) ឬក្រលួច ព្រមទាំងសម្ដែងធម៌ណែនាំ ប្រៀនប្រដៅដល់អ្នកភូមិជិតខាង ។ ផ្លូវថ្នេះហើយ ទើបកិត្តិយស និងកិត្តិនាម "ង៉ុយ" ល្បីសុះសាយ មិនតែប៉ុណ្ណោះសោត កសិករឯទៀតរាប់អានស្រឡាញ់ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយអ្នកភូមិទាំងអស់ សន្មត់ឈ្មោះលោកថា "ភិរម្យង៉ុយ" ។ សំនួនវោហារ ល្បីល្បាញ ខ្ទរខ្ទាររបស់កវីយើងនេះ បានលេចឮរន្ទឺដល់សម្ដេចចក្រី។ បានហៅង៉ុយឲ្យទៅច្រៀងថ្វាយស្ដេច ។ ព្រះបាទ ស៊ីសុវត្ថិ ទ្រង់ពេញព្រះទ័យជាទីបំផុត ទើបទ្រង់ប្រទានរង្វាន់ជាប្រាក់កាសដល់កវី ង៉ុយ ព្រមទាំងប្រទានគោរម្យងារជា "ព្រះភិរម្យភាសា" ។ គាត់ទទួលអនិច្ចកម្មក្នុងឆ្នាំ១៩៣៦ ។

## ២.៩ លោក ឌី ឈាង (ឆ្នាំកំណើត ?, ឆ្នាំមរណភាព ?)

នៅអំឡុងឆ្នាំ១៩៥០ លោកអ្នកប្រាជ្ញខ្មែររូបនេះបានមកធ្វើការសិក្សាស្រាវជ្រាវ និងបង្រៀននៅក្រុងប៉ារីស ។ ប៉ុន្តែ យើងខ្ញុំមានសេចក្ដីសោកស្ដាយយ៉ាងខ្លាំង ដោយយើងខ្ញុំពុំមានឯកសារអំពីជីវប្រវត្តិរបស់អ្នកប្រាជ្ញរូបនេះឲ្យបានក្បោះក្បាយសោះទេ (គាត់មានវ័យស្រករនិងសម្ដេច ព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាតដែរ) ។

ម្យ៉ាងទៀត ដោយយោងទៅតាមសន្តិសីទនានាដែលលោកស្រីបណ្ឌិតពៅ សាវរស បានធ្វើ

15 ភិរម្យភាសា អ៊ុក អ៊ូ ហៅ ង៉ុយ,
បណ្ដាំក្រមង៉ុយ, បោះពុម្ពជាថ្មីដោយ សេរ្វីរក, ឆ្នាំ១៩៨១ ។ -ច្បាប់ក្រមង៉ុយ : ច្បាប់ល្បើកថ្មី, ច្បាប់កេរកាលថ្មី, សេចក្ដីរំលឹកដាស់តឿន, ពាក្យកាព្យប្រដៅជនប្រុស-ស្រី, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ព.ស. ២៥១៦, គ.ស.១៩៧២ ។



ឡើងជាបន្តបន្ទាប់ កាលពីឆ្នាំ ១៩៨៨ ដល់ ១៩៩៤ នៅសាកលវិទ្យាល័យសិកបោនទំនើប ប៉ារីសទី៣ (Université Sencier Sorbonne Nouvelle, Paris III) ។ និងពីឆ្នាំ ១៩៩៥ ដល់ ១៩៩៨ នៅសាលាបារាំងចុងបូព៌ានោះ (Ecole Française d'Extrême-Orient, E.F.E.O.) ហើយដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវនៅពេលនោះដែរ បានឲ្យដឹងថា: លោក ឌី ឈាង ធ្លាប់បានបង្រៀនភាសាបាលី, ភាសាសំស្ក្រឹត និងសិលាចារឹកខ្មែរទៀតផង តែគាត់ពុំមានមុខងារអ្វីធំដុំក្នុងក្រសួងវប្បការបារាំងទេ ។ រីឯលោកស្រីពៅ សាវរស ក៏ត្រូវជាសិស្សរបស់គាត់មួយរូបដែរ ក្នុងចំណោមកូនសិស្សយ៉ាងច្រើនដទៃទៀត ។

សង្ខេបសេចក្ដីខ្លះមក លោកបានបន្សល់ស្នាដៃខ្លះ ដែលយើងខ្ញុំបានស្រាវជ្រាវយោងមកបង្ហាញជូនជនរួមជាតិឲ្យបានជ្រាប ដូចខាងក្រោមនេះ ១៦ ។

## ២.១០ លោក ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម (គន្ថរចនបណ្ឌិតនៃព្រះរាជបណ្ណាល័យកម្ពុជា), (ឆ្នាំកំណើត?, ឆ្នាំមរណភាព?)

លោកបានរៀបរៀងឡើងវិញ សិលាចារឹកទំនើបអង្គរវត្ត ។

នៅចុងសតវត្សទី១៩ ដើមសវ.ទី២០នេះ មានលោកអ្នកប្រាជ្ញម្នាក់មាននាមថា ឧកញ៉ា ទេពពិទូរ ឈឹម-ក្រសេម លោកមានមុខងារយ៉ាងសំខាន់ក្នុងព្រះរាជបណ្ណាល័យ កម្ពុជាគឺ :

-គន្ថរចនបណ្ឌិតនៃព្រះរាជបណ្ណាល័យកម្ពុជា,
-ជាអ្នកចាត់ចែងកម្មវិធីបង្រៀនក្នុងការសិក្សាបាលីនៅពុទ្ធិកសាកលវិទ្យាល័យ,
-លោកបានធ្វើសហការជាមួយអ្នកសិក្សាស្រាវជ្រាវបារាំងខ្លះ ទោះដោយប្រយោលក្ដី ដោយផ្ទាល់ក្ដី ដោយអណាមឹកក្ដី ដែលមានលោកសឺដេសជាអាទិ៍,
-លោកបានចូលរួមជាមួយគណកម្មការ នៃការនិពន្ធវចនានុក្រមខ្មែរ ជាមួយសម្ដេចព្រះ

16 Voir Au, Chhieng,
1. Catalogue du Fonds Khmer de la Bibliothèque Nationale, Paris Bibliothèque Nationale 1953.
2.a . Etudes de Philologie Indo-Khmère (I et II), *Journal Asiatique*, t. CCL, 1962 : 575-591.
b. Etudes de Philologie Indo-Khmère (III et IV), *Journal Asiatique*, t. CCLIV, 1966 : 143-161.
c. Etudes de Philologie Indo-Khmère (V), *Journal Asiatique*, t. CCLVI, 1968 : 185-201.
d. Etudes de Philologie Indo-Khmère (VI), *Journal Asiatique*, t. CCLIX, 1971 : 297-308.
e. Etudes de Philologie Indo-Khmère (VII), *Journal Asiatique*, t. CCLXII, 1974 : 131-141.
f. «Le nom postume du Roi Cambodgien Surāmarit», *Journal Asiatique*, t. CCLXXII, Fasc.3-4, 1984.

សង្ឃរាជ ជួន ណាត,

-និងជាពិសេសគាត់បានរៀបរៀង "សិលាចារឹកទំនើបអង្គរវត្ត"។ ស្នាដៃនោះ សេដូរិច (មជ្ឈមណ្ឌលឯកសារស្រាវជ្រាវវប្បធម៌ខ្មែរ) បានក្រងទំព័រ និងបោះពុម្ពសារជាថ្មីឡើងវិញ នៅឆ្នាំ១៩៨៤ [១៧] ។

២.១១ ព្រះភិក្ខុវីរិយបណ្ឌិតោ ជាំង ខាត់ (ឆ្នាំកំណើត ?, ឆ្នាំសុគត់ ?)

ស្នាព្រះហស្ត : ស្រីហិតោបទេស ៤ក្បាល

លោកបានសិក្សាជ្រៅជ្រះផ្នែកព្រះពុទ្ធសាសនា, ខាងធម៌អាថ៌, សំស្ក្រឹត-បាលី និងភាសាជាតិយ៉ាងជំនាញ ។ ព្រះអង្គបានយល់ដល់គុណសម្បត្តិនៃរឿងស្រីហិតោបទេស ។ ព្រះអង្គបានចំណាយពេលខិតខំប្រឹងប្រែងប្រែ រឿងស្រីហិតោបទេស ពីភាសាសំស្ក្រឹតមកជាភាសាខ្មែរសម្រាយ ដើម្បីឲ្យកុលបុត្របានសិក្សា ពិចារណា ស្រាវ ស្រង់យកទស្សនៈផ្សេងៗ មកជាវិជ្ជាសម្រាប់ត្រិះរិះក្នុងក្រសែជីវិត ។

រឿងនេះ បាប់បោះពុម្ពជាលើកទីមួយនៅគ.ស.១៩៤៩ មានគោលការណ៍បួនប្រការដែលសំខាន់ៗក្នុងផ្ទៃរឿង: ១. ការគប់មិត្ត ។ ២. ការបំបែកមិត្ត ។ ៣. សេចក្ដីសាមគ្គី ។ ៤.សន្តិភាពនៃសត្វលោក [១៨] ។

២.១២ សម្ដេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត (ព្រះសង្ឃនាយកគណៈមហានិកាយ, ព.ស.២៤២៦-២៥១២, គ.ស.១៨៨៣-១៩៦៩)

ស្នាព្រះហស្ត :ព្រះត្រៃបិដក, "វចនានុក្រមខ្មែរ" ២ ក្បាល [១៩] និងសៀវភៅធម៌ជាច្រើន ...។

យើងខ្ញុំសូមអភ័យទោសពីសំណាក់មិត្តអ្នកអានជាមុនថា យើងខ្ញុំពុំបានធ្វើអត្ថាធិប្បាយឲ្យបានក្បោះក្បាយអំពីព្រះជីវប្រវត្តិដ៏វែង ហើយសំខាន់របស់ព្រះអង្គទេ សូមអញ្ជើញអានស្នាព្រះហស្តព្រះមុនីកោសល សួរ ហាយ ស្ដីអំពី "ព្រះរាជជីវប្រវត្តិនៃសម្ដេចសង្ឃរាជជួន ណាត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ឆ្នាំ១៩៩៣ [២០] ទើបបានក្បោះក្បាយ ។ រីឯយើងខ្ញុំមានគោលបំណង

17 Mohā Bidūr Chhim Krassem,
a. Silācārịk Nokor Vatt niṅ padānukramṃ (Insciptions Modernes d'Angkor Vat et Lexique), 2ème Edition, Phnom Penh, 1958.
b. Insciptions Modernes d'Angkor Vat, *Cedoreck*, 1984.



បំផុសស្នាព្រះហស្តរបស់ព្រះអង្គដែលសំខាន់ ជាពិសេសក្នុងបេសកកម្មស្រាវជ្រាវពីភាសា, អក្សរសាស្ត្រខ្មែរ និងវប្បធម៌ជាតិ ។ ដោយឡែកអំពីកិច្ចការសព្វសារពើដែលជាព្រះរាជបុគ្គអ្ន ក្នុងផ្នែកព្រះពុទ្ធសាសនា និង ផ្នែកកិច្ចការខាងអាណាចក្រជាច្រើនអនេក ពុំអាចគណនាបាន ដែលព្រះអង្គបានព្រះរាជទាន : -ខាងការស្ថាបនាវត្តអារាម, -ខាងការស្ថាបនាសាលារៀន, -សាងមន្ទីរពេទ្យ, -សាងគមនាគមន៍, -សាងស្ពាន ស្រះ, ទំនប់ទឹក, -សាងសហករណ៍, -សាងឈាបនដ្ឋាន... ។

១. ឋានន្តរស័ក្តិ និងការបង្ហាត់បង្ហាញរបស់ព្រះអង្គដល់ព្រះភិក្ខុសង្ឃ :

-ពីគ្រិស្តសករាជ១៩២៦ តមកជាច្រើនឆ្នាំ សម្ដេចបានទទួលការតែងតាំងជាមេប្រយោគក្នុងការប្រឡងវិញ្ញាបនប័ត្របឋមសិក្សាខ្មែរ និងការប្រឡងវិញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ បារាំង-ខ្មែរ នៅក្រុងភ្នំពេញ ។

-គ.ស.១៩២៥ សម្ដេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានា ដែល

18 ព្រះភិក្ខុវីរិយបណ្ឌិតោ ជាំង ខាត់,
-ស្រីហិតោបទេស ភាគទី១, បណ្ណាគារ គឹម គី, ភ្នំពេញ ព.ស.២៥១៧, គ.ស.១៩៧៣ ។
-ស្រីហិតោបទេស ភាគទី២, បណ្ណាគារ គិម សេង, ភ្នំពេញ ព.ស.២៤៩៨, គ.ស.១៩៥២ ។
-ស្រីហិតោបទេស ភាគទី៣, បណ្ណាគារ គិម សេង, ភ្នំពេញ ព.ស.២៥០៣, គ.ស.១៩៦០ ។
-ស្រីហិតោបទេស ភាគទី៤, បណ្ណាគារ គិម សេង, ភ្នំពេញ ព.ស.២៥០៣, គ.ស.១៩៦០ ។

19 ក. ស្នាព្រះហស្តខ្លះៗ :
-មហាបុរិសលក្ខណៈ, បណ្ណាល័យព្រះរាជវាំង, ភ្នំពេញ គ.ស.១៩៣៥, ៦៤ទំព័រ ។
-នាគោបមាទិកថា, បណ្ណាល័យព្រះរាជវាំង, ភ្នំពេញ គ.ស.១៩៣៣, ២០ទំព័រ ។
-វិន័យបដិមោខសំវរសិលសំខេប នឹងខន្ធកវិន័យសំខេប, រោងពុម្ពរដ្ឋាភិបាល, ភ្នំពេញ គ.ស.១៩២៨, ៩៣ទំព័រ ។
ខ. វចនានុក្រមខ្មែរ, ភាគទី១, បោះពុម្ពគ្រាទី៥, ដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ព.ស.២៥១១, គ.ស.១៩៦៧ ។ វចនានុក្រមខ្មែរ, ភាគទី២, បោះពុម្ពគ្រាទី៥, ដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ព.ស.២៥១២, គ.ស.១៩៦៨ ។

20 សូមអានស្នាព្រះហស្ត ព្រះមុនីកោសល សួរ ហាយ ស្ដីអំពី "ព្រះរាជជីវប្រវត្តិនៃសម្ដេចសង្ឃរាជ ជួន ណាត" បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ឆ្នាំ១៩៩៣ ។

សាលាបាលីជាន់ខ្ពស់នឹងរៀបចំបោះពុម្ពផ្សាយ ។

-គ.ស.១៩៣០ សម្តេចបានទទួលការតែងតាំងក្នុងមុខងារជាចាងហ្វាងរង នៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។ ក្នុងឆ្នាំដដែលនោះ សម្តេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

-គ្រិស្តសករាជ១៩៣៥ សម្តេចបានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី, សំស្ក្រឹត, ខ្មែរប្រចាំថ្នាក់បញ្ចប់នៃមធ្យមសិក្សា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។

-គ.ស.១៩៤២ សម្តេចបានទទួលឋានន្តរសក្តិជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ជាថ្មីទៀត ក្រុងភ្នំពេញ ។

-គ.ស.១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់បានថ្វាយព្រះឋានន្តរសក្តិសម្តេច ជាព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ ។

-ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៦៧ សម្តេចបានទទួលសញ្ញាប័ត្របណ្ឌិតអក្សរសាស្ត្រពេញលក្ខណៈពីមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រកម្ពុជា ។

-គ.ស.១៩៦៨ សម្តេចបានទទួលការតែងតាំងជាប្រធានគណកម្មការពិនិត្យអត្ថបទផ្សាយ ខាងប្រវត្តិសាស្ត្រខ្មែរ ។

២. ការស្រាវជ្រាវរបស់ព្រះអង្គអំពីភាសា, អក្សរសាស្ត្រ, និងវប្បធម៌ជាតិ ។ ការបោះពុម្ពមួយលើកជាពីរលើក ។ ព្រះអង្គបានស្រាវជ្រាវរកពាក្យ, បង្កើនពាក្យ, រិះរកពាក្យខ្មែរដែលបាត់បង់ ឬ លាក់កប់នៅទីផ្សេងៗ (ក្នុងកំណាព្យសម័យចាស់, ក្នុងអក្សរសាស្ត្រសម័យចាស់, សម័យកណ្តាល...។

-គ្រិស្តសករាជ១៩៣២ សម្តេចបានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសរកពាក្យពេចន៍ក្នុងស្នាដៃនៃកវីខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យពេចន៍ទាំងនោះទៅក្នុងវចនានុក្រមខ្មែរ ។

-គ្រិស្តសករាជ១៩៣៤ សម្តេចបានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសរកពាក្យពេចន៍ខ្មែរ ប្រៀបធៀបនិងពាក្យបារាំងសម្រាប់ប្រើក្នុងកិច្ចការរាជការ ។

៣. គ.ស.១៩១៩ សម្តេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងនិពន្ធនៃវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់លុះត្រាបានចប់ចុងចប់ដើម ។

-គ.ស.១៩២៧ សម្តេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរហើយ



សម្តេចទ្រង់បានទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គឯងដរាបដល់សព្វគ្រប់បានបោះពុម្ពផ្សាយជាច្រើនលើក ច្រើនគ្រា ។ ការប្តូផ្តាច់របស់ព្រះអង្គសាងវចនានុក្រមជាមហាវណ្ណកម្ម, ជាមហាជង្រុកនៃភាសាអក្សរសាស្ត្រខ្មែរ ។

ជារៀងរាល់ថ្ងៃ សម្តេចគ្មានឱកាសទំនេរល្ហែព្រះកាយបន្តិចណាទេ ។ ពេលព្រឹកខ្លះ ដោយជក់និងព្រះរាជកិច្ចក្នុងការិយាល័យរបស់ព្រះអង្គ ព្រះអង្គទ្រង់ភ្លេចទាំងសោយយាគូថែមទៀត ។ ទាំងថ្ងៃ ទាំងយប់ ព្រះអង្គមានកម្មវិធីមមាញឹកស្ទើរដកឃ្លាពុំបាន ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ព្រះអង្គនៅតែឆ្លៀតពេលសិក្សាព្រះអង្គឯង និង បង្រៀនដល់អ្នកដទៃដោយទៀងទាត់ឥតខកខានឡើយ ។

ព្រះគុណសម្បត្តិរបស់សម្តេចមានច្រើនប្រការណាស់ ប៉ុន្តែ យើងខ្ញុំអាចស្រង់សង្ខេបតែគោលសំខាន់ប្រាំប្រការ ដូចខាងក្រោមនេះ :

-វីរយភាព, បានដល់សេចក្តីព្យាយាមរបស់ព្រះអង្គក្នុងការសិក្សា ក៏ដូចជាធ្វើឲ្យសម្រេចស្នាព្រះហស្តនិមួយៗ, តាំងពីវ័យកុមាររហូតដល់វ័យជរា ។

-បដិភាណប្បញ្ញា, បានដល់ប្រាជ្ញាវាងវៃរបស់ព្រះអង្គ បានន័យថា ពូកែចាំ ពូកែគិត ពូកែឆ្លើយដោះប្រស្នាបានភ្លាមៗ ។

-វេសារជ្ជប្បញ្ញា, គឺជាប្រាជ្ញាពិសេសមួយដែលកេទជាអ្នកបួសជាច្រើនកម្រមាននោះ ពោលគឺប្រាជ្ញា រួមផ្សំនិងឆន្ទៈមោះមុតក្លៀវក្លា, ហ៊ានគិតឲ្យបានត្រឹមត្រូវ, ហ៊ានធ្វើឲ្យបានត្រឹមត្រូវ, ហ៊ានទទួលខុសត្រូវ ។ លក្ខណៈដ៏ប្រពៃកម្រមាននេះ បានធ្វើឲ្យព្រះអង្គបានសម្រេចនូវព្រះរាជបេសកកម្មជាច្រើនតាមឆន្ទៈរបស់ព្រះអង្គ ។ ដោយសារតែព្រះអង្គមានវេសារជ្ជប្បញ្ញានេះ ពេលសម្តេចយាងទៅកាន់ទីប្រជុំធំៗក្នុងប្រទេសក្តី ក្រៅប្រទេសក្តី ព្រះអង្គតែងតែធ្វើឲ្យមហាជនកោតស្ញប់ស្ញែងស្ងួរសីហនាទដ៏ក្រនិងក្រនី, ព្រះភ័ក្ត្រដ៏អង់អាចក្លៀវក្លាឥតញាប់ញ័រតក់ស្លុតរបស់ព្រះអង្គ ។

-ធម្មទេសនាកោសល្យ, ចំណែកលក្ខណៈពិសេសមួយទៀតដែលជាការចាំបាច់របស់អ្នកបួសនោះគឺការឈ្លាសវៃក្នុងធម្មទេសនា ។ ដោយសារតែព្រះអង្គមានលក្ខណៈសម្បត្តិមុនៗជាមូលដ្ឋាន ព្រះអង្គក៏បានឈានទៅដល់ធម្មទេសនាកោសលយ៉ាងខ្ពស់ ។ ធម្មទេសនានៃសម្តេចមានខ្លឹមសារ ប្រកបដោយប្រយោជន៍ទាំងផ្លូវលោក ទាំងផ្លូវធម៌ ។ អាចបំភ្លឺពុទ្ធបរិស័ទ ប្រជាពលរដ្ឋ ឲ្យយល់ផ្លូវខុសផ្លូវត្រូវ ឲ្យមានសេចក្តីព្យាយាម មានជំហររឹងប៉ឹង ឲ្យប្រឹងប្រែងប្រកបការងារ កុំឲ្យខ្ជិលច្រអូស ឲ្យ

មានធម៌សាមគ្គីមូលមិត្ត ឯកភាពក្នុងសាសនា ឯកភាពក្នុងប្រយោជន៍ជាតិ ជាដើម...។ -បណីតសកម្មភាព,ការងារទាំងឡាយរបស់ព្រះសង្ឃនាយក សុទ្ធសឹងតែជាការងារមានប្រយោជន៍ឧត្តុង្គឧត្តមណាស់ ចំពោះការស្រាវជ្រាវរបស់ព្រះអង្គអំពីភាសា, អក្សរ, វប្បធម៌ជាតិ ។

ព្រះអង្គជាកវី-និពន្ធមួយអង្គយ៉ាងសម្បើម ដែលមានស្នាព្រះហស្ត : ព្រះត្រៃបិដក, វចនានុក្រមខ្មែរ និង កំពីជទៃទៀតនៃពុទ្ធសាសនា (សូមអានឯកសារយោង លេខ១៩ ខាងដើមនេះ) ។

ទីបញ្ចប់ យើងខ្ញុំសូមលើកយកឃ្លារបស់ក្រុមអធិបតិ និង ក្រុមជំនុំពុទ្ធសាសនបណ្ឌិត្យមួយវគ្គមកបញ្ជាក់ជូន ឲ្យយើងទាំងអស់បានដឹងយល់អំពី "ធម៌វិរយំ" ដ៏ខ្ពង់ខ្ពស់របស់ទ្រង់ដើម្បីឲ្យបានសម្រេចបំណងអ្វីនីមួយៗ ជាបន្ទាល់ដូចខាងក្រោមនេះ :

..."លុះមកដល់អវសាន, ព្រះពុទ្ធឃោសាចារ្យជួន ណាត បានបើកែធ្វើជាថ្មីឡើងម្តងទៀតដោយសេចក្តីខំប្រឹងពេញកម្លាំងតែមួយរូបគត់ ឥតមានលោកណាជាគម្រប់ពីរឡើយ ជាដីរាបទាល់តែហើយការស្រេច កើតបានជាវចនានុក្រមខ្មែរនេះឡើង ជាការកើតដំបូងបំផុត ក្នុងកម្ពុជរដ្ឋ" (សូមអញ្ជើញអាន អធិបតិ និង ក្រុមជំនុំពុទ្ធសាសនបណ្ឌិត្យ, វចនានុក្រមខ្មែរ ក្បាលទី១ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ទំព័រ ថ) ។

ដូច្នោះ ស្នាព្រះហស្តរបស់ព្រះអង្គ ប្រៀបដូចខ្សាច់នៅតាមឆ្នេរនៃមហាសមុទ្រពុំអាចរាប់បាន។

ទស្សនៈរបស់សម្តេចទៅអនាគតចំពោះ"វចនានុក្រមខ្មែរ" ឬ បណ្តាំរបស់ព្រះ អង្គ :

សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត ទ្រង់មានព្រះពុទ្ធដីការថា : ក. ..."*វចនានុក្រមខ្មែរទាំង២ភាគ ដែលបោះពុម្ពគ្រាទី៥នេះ ទូលំទូលាយគ្រាន់បើបន្តិចជាងមុន, ប៉ុន្តែបើធៀបប្រៀបទៅនឹងផ្លូវ ក៏មានឋានៈត្រឹមតែប្រហែលនឹងថ្នល់ដែលបានចាក់រាយគ្រួសចាយក្បៀមស្តើងៗប៉ុណ្ណោះ ពុំទាន់មានឋានៈស្មើនឹងថ្នល់ដែលចាក់ជ័រយ៉ាងក្រាសរលើបរលង់នៅឡើយទេ, ក្នុងអនាគតមិនយូរឆ្នាំប៉ុន្មាន ទើបអាចនឹងឡើងឋានៈ និងថ្នល់ចាក់ជ័ររលង់រលើបពុំខានឡើយ, គួរឲ្យខ្ញុំទឹកស្តាយណាស់ដោយមិនបានឃើញ ឋានៈខ្ពង់ខ្ពស់របស់វចនានុក្រមខ្មែរនេះ...!*" (វចនានុក្រមខ្មែរ ក្បាលទី១ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ទំព័រ ង) ។ ខ. ..."*ពុទ្ធសាសនបណ្ឌិត្យមានបំណងថា លុះដល់បើបោះពុម្ពឡើងវិញក្នុងគ្រាក្រោយៗ នឹងលៃលកបន្ថែមមេពាក្យខ្វះទាំងនោះតៗទៅទៀត ដើម្បីឲ្យមានគ្រប់គ្រាន់ឡើង...*" (វចនានុក្រមខ្មែរ ក្បាល ទី១ បោះពុម្ពគ្រាទី៥ ឆ្នាំ ១៩៦៧ ទំព័រ ឈ) ។



ដូច្នេះ ពីមួយឆ្នាំទៅមួយឆ្នាំ ជាធម្មតា "វចនានុក្រម" ត្រូវតែសើរើរកបន្ថែមពាក្យថ្មីៗ នឹងបោះពុម្ពឡើងវិញជាដរាប ហើយនេះបើតាមការយល់ឃើញរបស់យើងខ្ញុំ គឺជាបណ្តាំ និងកិច្ចអំពាវនាវរបស់ព្រះអង្គដល់បញ្ញវន្តជំនាន់ក្រោយៗទៀតផង ដែលមានភារកិច្ចនឹងបន្ត "វចនានុក្រមខ្មែរ" ទៅអនាគត ។

## ៣. កំណត់ឯកសារ

សំណេរនីមួយៗក្នុងចំណោមសំណេរទាំងពីរ ដែលយើងខ្ញុំមាន យើងខ្ញុំបានរាប់ឃើញ ៥៤៥ វគ្គ ដូចគ្នា ។ រីឯរបៀបនិពន្ធក៏ដូចគ្នាដែរ ។ យើងខ្ញុំនឹងចាប់ផ្តើមលើកឡើងមកអត្ថាធិប្បាយខ្លីៗអំពីសំណាដៃទីមួយនេះ ហើយបន្ទាប់ទៅយើងខ្ញុំនឹងចាប់យកសំណាដៃទីពីរ ដើម្បីធ្វើអត្ថាធិប្បាយឲ្យបានស្មោះក្បាយបន្តិច ដូចតទៅនេះ :

៣.១ ដំបូងបង្អស់ យើងខ្ញុំនឹងលើកយកសំណាដៃដើម ដែលបោះពុម្ពក្រោមការពិនិត្យពិច័យនៃលោក អេម៉ូនីញេ អេត្វែន (Aymonier Etienne) មកពិពណ៌នា ។ សំណាដៃទីមួយនេះ ស្ថិតនៅក្នុងកម្រងអត្ថបទមួយដែលមានឈ្មោះថា "អត្ថបទខ្មែរ" (Textes Khmers) បោះពុម្ពផ្សាយនៅក្រុងព្រៃនគរ ឆ្នាំ១៨៧៨ ។ កម្រងអត្ថបទនោះ ចាប់ផ្តើមឡើងដោយប្រែសំណៅជាភាសាបារាំង (Textes Traductions 84 p) ហើយបន្ទាប់មកគឺអត្ថបទជាភាសាខ្មែរ ដែលត្រូវចែកជាពីរផ្នែកទៀតគឺ : ក. រឿងនិទានបី ។ ខ. រឿងនិទានមាយើង (Mā Yœuṅ) និង ល្បើកនគរវត្ត (Edification d'Angkor Vatt) ។ ល្បើកនគរវត្តនេះ ត្រូវបានចម្លងឡើងសារជាថ្មី ជា "អក្សរមូល" (Mūl) ដោយលោក សើន ឌៀព [២១] ។

៣.២ បន្ទាប់ទៅទៀត យើងខ្ញុំនឹងនិយាយអំពីសំណាដៃទីពីរដែលជាបន្ទាប់បន្សំ និងឥតបានបោះពុម្ពផ្សាយទេ ជាសំណាដៃដែលដំកល់នៅ "សូស៊ីយ៉េតេ អាស៊ីយ៉ាទិក" (Société Asiatique, coté B. 39) ។ សំណាដៃទីពីរនេះ ជាសំណាដៃសរសេរដោយផ្ទាល់ដៃលើក្រដាសដោយគ្មានចុះ

21 នៅឆ្នាំ១៩០៨ លោកសើន ឌៀព ត្រូវបានតែងតាំងជាឧញ្ញាក្រឡាហោម, ខ្មែរទំនើបហៅថា រដ្ឋមន្ត្រីទ័ពជើងទឹក ។ សូមអាន ស្នាដៃរបស់លោក, ល្បើកលើកតាមផ្លូវទៅស្រុកបារាំងែស នៅទីតាំតុ នៅក្រុង បារីស៍ ឆ្នាំ១៩០០, រោងពុម្ព ប៊ុង បារីស៍, នៅឆ្នាំ១៩០១, ៤៤ ទំព័រ ។

កំណត់អ្វី និងគ្មានថ្ងៃខែទេ ឬ ម្យ៉ាងទៀត គ្មានកំណត់សំគាល់អ្វីសោះថា ចម្លងមកពីសាស្ត្រាស្លឹករឹតណាក៏ទេដែរ ។ សំណាដៃនេះសរសេរជាអក្សរគ្រវាស់ ឬ ហៅថា "អក្សរជ្រៀង" ។

ដូចយើងខ្ញុំបានជម្រាបខាងលើបន្តិចហើយ សំណាដៃទីពីរនេះមានវគ្គស្មើគ្នា និងរបៀបនិពន្ធរហូតដល់លំអិតខាងភាសាសាស្ត្រ ជាពិសេសអត្ថន័យនៃពាក្យក៏ដូចគ្នា និងសំណាដៃទីមួយ ។ មានឃើញខុសប្លែកគ្នាខ្លះ តែអំពីអក្ខរាវិរុទ្ធតែប៉ុណ្ណោះ ប៉ុន្តែ ពុំមានគុណវិបត្តិអ្វីធំដុំដល់អត្ថបទទេ ។ "ល្បើកនគរវត្ត" ឬ "កំណាព្យអង្គរវត្ត" (LNV.) នោះ យើងខ្ញុំបានស្រង់យកស្នាដៃ ដែលលោកអេម៉ូនីញេ បានបោះពុម្ពក្នុងសៀវភៅមួយដែលមានឈ្មោះថា ប្រជុំអត្ថបទខ្មែរ (បោះពុម្ពនៅឆ្នាំ ១៨៧៨ ទំព័រទី២៦៥ ដល់ ២៩៧) ។ ក្នុងកំណាព្យនោះ មានវគ្គយ៉ាងច្រើនដែលធ្វើអត្ថាធិប្បាយតាមចម្លាក់ភ្ជាប់នៅនឹងជញ្ជាំងថែវនៃប្រាសាទអង្គរវត្ត ដែលមានផ្ទាំងមួយនោះអត្ថាធិប្បាយឲ្យយើងបានដឹងអំពីសកម្មភាពរបស់ព្រះរាម (Rāma, វគ្គ ២០៤-៤២៥) ។

## ៤. ជីវប្រវត្តិ និង ការរកិច្ចដល់សាសនានៃអ្នកនិពន្ធ

### ៤.១ ជីវប្រវត្តិ

ព្រះសង្ឃខ្លះបានប្រគល់ភារៈខាងចារដល់យុវសាមណេរ (យុវសង្ឃ) ដោយបង្ហាត់ហ្វឹកហ្វឺនឲ្យនិពន្ធកំណាព្យ និងចារអក្សរលើស្លឹករឹតផង ។ ការផ្សព្វផ្សាយរបៀបនេះបានភ្ជាប់យ៉ាងជ្រៅនូវវិជ្ជាផ្សេងៗ ទៅនឹងប្រពៃណីខ្មែរ សម័យកណ្ដាល (ស.វ.១៦ ដល់ ១៨) ។ តាមមតិរបស់យើងខ្ញុំ ចាំង តាត ជាអ្នកទទួលមត៌កនៃវប្បធម៌អង្គរ ជាអ្នកសិក្សា និងបន្តចំណេះវិជ្ជានេះប្រកបដោយទេពកោសល្យនិពន្ធកំណាព្យដ៏ប្រសើរ ។

បន្ទាប់មកទៀត អ្នកនិពន្ធ បានប្រាប់ឈ្មោះខ្លួនគាត់ នាមគាត់គឺ ចាង តាត ក្នុងសំណាដៃទី១ និង ចាំង តាត់ ក្នុងសំណាដៃទី២ ដូចសួរស័ព្ទ [ចាង តាត] ដែលយើងខ្ញុំសូមចម្លងឡើង វិញថា "ចាំង តាត" ។

ពាក្យពីរ-បី បន្តបន្ទាប់ ខាងមុខនាមរបស់គាត់មានអត្ថន័យយ៉ាងធ្ងន់ ។ ដូចជាអម្បូរ (ampūr), ពូជ (būj), ពង្ស (bans), ត្រកូល (trakūl), ជាតិ (Jāti), វង្ស (Vans), ដែលមានអត្ថន័យប្រហាក់ប្រហែលគ្នា (Synonymes), ដោយយោងទៅលើពាក្យ "គ្រួសារ, សន្តាន, ញាតិផៅ" ដែលមានអត្ថន័យ ខ្ពង់ខ្ពស់ទៅទៀតក្នុងសង្គម : គុណសម្បត្តិ (laqualité), ឧត្តុង្គឧត្តម (la



supériorité) ។ សក្ដីភាពនេះមាននៅក្នុងសទ្ទានុក្រម : អ្នកកវីខ្លួនគាត់បានបញ្ជាក់ថា គាត់មាន "អម្បូរ (ampūr), ពូជ (būj), ... ។ល។ គឺជាឫសគល់នៃគ្រួសារ ។

គាត់បានបញ្ជាក់ដោយខ្លួនគាត់ផ្ទាល់ថា គាត់មានពូជពង្សល្អ (bonne naissance), ហើយគេពុំសង្ស័យទេថា ដើម្បីលើកដម្កើងខ្លួនឯងទេ ប៉ុន្តែ ជាពិសេសទៅវិញ ដើម្បីលើកស្ទួយ ដម្កើងផៅពង្ស សន្តានរបស់គាត់ ដែលមានជាឧត្តមបិតា-មាតារបស់គាត់ ។ ទោះជាយ៉ាងណាក្តី ចំពោះអ្នកនិពន្ធទាំងអស់ដែលគាត់ស្ថិតនៅក្នុងសង្គមដ៏ខ្ពង់ខ្ពស់នេះ ក៏ជាច្បាប់ទូទៅគ្រប់ប្រទេស ទោះមានបំណងក្តីពុំមានបំណងក្តី ។

ម្យ៉ាងទៀត គាត់បញ្ជាក់ខ្លួនគាត់ថាជា "កវីបណ្ឌិត", (Kavipaṇḍit) គឺ -ជាអ្នកប្រាជ្ញសម័យគាត់, អ្នកអក្សរសាស្ត្រ ឬ ជាព្រឹទ្ធាចារ្យទៀតផង ។ -ថាគាត់ក្លាយទៅជាអ្នកមាន "តម្រិះអស្ចារ្យនិងវិទ្យា" (l'éloquence et la science) ។ -ថាជាព្រឹទ្ធាចារ្យដែលពោរពេញដោយចំណេះវប្បធម៌ជាឧបករអាចបង្កើត បម្រើក្នុងការបន្តចំណេះ និងទំនឹម ។ ភាពល្បីល្បាញរបស់គាត់នៅក្នុងសង្គមអាចហៅនាមរបស់គាត់ឲ្យលើសនិងពាក្យខ្ពង់ខ្ពស់មួយមាត់ថា "លោក" ដែលពាក្យដើមជាពាក្យសំស្ក្រឹត (Ces Messieurs) ។ មានកវីភាគច្រើនអាចឡើងឋានន្តរសក្តិដល់ខ្ពង់ខ្ពស់ទៀតក៏មាន នៅក្នុងសង្គមដោយសារទេពកោសល្យ (talents) របស់គាត់ ។ ព្រះមហាក្សត្រិយ៍ជ្រើសរើសអស់លោកព្រឹទ្ធាចារ្យទាំងនោះ ហើយទទួលយ៉ាងឧត្តុង្គឧត្តមឲ្យទៅជា "រាជបរិស័ទ" (rājaparisad) ហើយគាត់តាំងនៅជិតជុំជាក្រុមជាមួយព្រះសង្ឃ, ជាមួយព្រាហ្មណ៍ និងជាមួយឧត្តមមន្ត្រីនៃព្រះមហាក្សត្រិយ៍ទៀតផង ។ សក្តីភាពទាំងនេះ គេឃើញបញ្ជាក់យ៉ាងច្បាស់នៅក្នុងបុព្វកថានៃក្រម (Kram) ផ្សេងៗ ។

### ៤.២ ការរកិច្ចដល់សាសនា និង ជំនឿរបស់គាត់

ក្រោយពីការបង្ហាញក្នុងជំពូកដើមដោយស្ងប់ស្ងាត់ តែមានខ្លឹមសារយ៉ាងប្រសើរមក អ្នកកវីក៏សូមក្រាបថ្វាយបង្គំដល់ព្រះពុទ្ធ ដោយសេចក្តីសរសើរដ៏ខ្ពង់ខ្ពស់ក្រៃលែង និងថ្វាយបង្គំដល់ព្រះស្រីអារ្យ ដែលទ្រង់នឹងត្រាស់ដឹងនៅពេលអនាគត ។ បន្ទាប់មកទៀត ជាសំណូមពររបស់គាត់សុំឲ្យបានទទួលជោគជ័យជាធម្មតាដូចកំណាព្យរបស់គាត់ ។

យើងខ្ញុំសូមកត់សំគាល់បន្តិចថា នៅក្នុងវគ្គនេះ គាត់សង្កត់យ៉ាងខ្លាំងទៅលើទស្សនៈនៃព្រះពុទ្ធ

(Loi du Bouddha, Dharmma) ប៉ុន្តែប្រាកដជា គាត់ពុំចោលសោះទេនូវទស្សនៈព្រហ្មញ្ញសាសនា គឺ ត្រៃភេទ, (traibhed) ។ គាត់បានកំណត់ទៀតថា កំណាព្យរបស់គាត់ទុកដូចជា "ច្បាប់" (Cpāp') (វគ្គទី២) ដើម្បីជាសេចក្ដីចំរើនតាមគន្លង និងវិធីពីបូរាណ ។ គាត់បានបញ្ចេញពោរពេញទៅដោយ "សទ្ធា" (saddhā) ចំពោះព្រះអង្គដែលទ្រង់គង់លើកំពូលបល្ល័ង្កដ៏អស្ចារ្យ ដោយគាត់គ្រាន់តែបានថ្វាយបង្គំគោរពដោយអាលោះអាល័យ គ្រាន់តែបានឃើញព្រះអង្គលើបល្ល័ង្ក ពុំបាន ស្ដាប់ឮព្រះអង្គសំដែងព្រះធម៌ (sa Loi dharmma) ឡើយ ។ ចាប់តាំងពីវគ្គទី២៤មក អ្នកកវីបានប្រកាសយ៉ាងឆាប់រហ័សតែម្ដង ប្រកាសអំពីប្រភេទស្នាដៃរបស់គាត់ និងស្ងូត្រជម្លើងសរសើរដល់ប្រាសាទ (prāsād), ដោយសង្កត់យ៉ាងខ្លាំងថា ប្រាសាទនោះត្រូវស្ថាបនាឡើងតាមបញ្ជានៃព្រះឥន្ទ្រ ដើម្បីទុកឲ្យបុត្ររបស់ទ្រង់ជាមនុស្សនាម "ព្រះកេតុមាលា" (Braḥ Ketumālā) ។ ប្រាសាទនេះត្រូវសាងតាមគម្រូឲ្យដូចជាប្រាសាទពេជ្ជយន្ត (Bejayant) នៃស្ថានព្រះឥន្ទ្រ ដែលលោកកវីគាត់ចងក្រងឡើងតាមពាក្យឃ្លាធម្មតារហូតដល់វគ្គទី៨៤ ។ បន្ដពីនោះទៅ គាត់ចាប់និពន្ធអំពីការស្ថាបនាប្រាសាទអង្គរវត្ត, មហារាជវាំងនៅលើដីនេះដែលមាន "ព្រះពិស្ណុការ" ជាមេបញ្ជាការធំនៃការសង់នោះ ។ បន្ទាប់មកទៀត ជាការអត្ថាធិប្បាយយ៉ាងវែងអំពីប្រាសាទ (prāsād) ធ្វើឲ្យពីរោះយ៉ាងអស្ចារ្យជាប់ត្រចៀក បង្កើតការលើកសរសើរ បង្កើតការបត់បែនឃ្លាប្រយោគ និងមានវគ្គផ្ទួនគ្នាទៅមកត្រង់ចំណុចដែលពេញចិត្តរបស់គាត់ ។ ប៉ុន្តែ មានវគ្គខ្លះមានទម្ងន់ ហើយមានពេលខ្លះក៏មានចាប់ចុងប្រយុងដើមដែរ តែជាធម្មតានៃការនិពន្ធនាសម័យនោះ (ដោយពុំបានរៀបចំគម្រោងទេ?) ។

ខាងក្រោមនេះ ជាប្រធានខ្លះដ៏មានតម្លៃរបស់កវី :

-ស្ថាបត្យកម្មនៃប្រាសាទ (Architecture du prāsāda) ដែលដំបូលសង់ដោយកំពូលច្រូងច្រាងហៅថា "ប្រាសាទ" ដែរ ។

-តាមជញ្ជាំងមានចម្លាក់លំអដោយទេពអប្សរ ។

-តាមថែវមានចម្លាក់ក្រឡោតនៃមហារឿងរាមកេរ្តិ៍ខ្មែរ ។

-តាមថែវមានក្បួនដង្ហែព្រះមហាក្សត្រិយ៍ជាព្យុះយាត្រានៃវរហ៏សេនាពលរបស់ព្រះកេតុមាលា (ឬព្រះនាមពិតគឺ សូរ្យវម្ម័ទី២ ឬ បរមវិស្ណុលោក (Sūryavarmma ou Paramaviṣṇuloka) ។

-នៅទីបញ្ចប់ថែវដែលមានចម្លាក់ក្រឡោតចែងអំពីស្ថានសួគ៌ និងស្ថាននរក ។



លោកអ្នកអាន ឬ អ្នកស្ដាប់ខ្លះបានបណ្ដែតអារម្មណ៍ឲ្យពុះកញ្ជ្រោលទៅតាមវិធីនិពន្ធរបស់កវីគឺ :

-បណ្ដែតអារម្មណ៍ស្រមើស្រមៃជាមួយនាងទេពអប្សរនាស្ថានត្រៃត្រឹង្សាគឺស្ថានសួគ៌នៃព្រះឥន្ទ្រតាមរយៈចម្លាក់បដិមានៃអង្គរវត្ត ។

-ផ្ដុំអារម្មណ៍ ក្នុងការសរសើរយ៉ាងលើសលុបទៅលើស្ថានសួគ៌ នាំឲ្យភ្ញាំងភ្ញឹកស្មារតីដល់ភាពល្បីល្បាញរន្ទឺ (Kerti, gloire) របស់ព្រះមហាក្សត្រិយ៍សម័យអង្គរ។ ពីសភាពដែលពុះកញ្ជ្រោលយ៉ាងខ្លាំង, យ៉ាងចាប់ចិត្ត ត្រូវស្ងប់ស្ងាត់យ៉ាងរហ័សមកវិញ ។ ហេតុអ្វី? ហេតុតែស្ដាយ, ស្រណោះ ។

ដើម្បីសង្រួមយោបល់នៃកំណាព្យដ៏ជោគជ័យនោះមកគឺ មានតែពីរវគ្គ នៅទីបញ្ចប់ដែលពោរពេញដោយ "សុភមង្គល និង សន្តិភាព" (Bonheur et de la paix) ។

## ៥. ឆ្នាំនិពន្ធ

លំនាំដើមនេះ កវីផ្ដើមឡើងចែងអំពីថ្ងៃខែដែលគាត់និពន្ធ (La date) ។ ដើម្បីឲ្យដឹងប្រាកដច្បាស់ យើងខ្ញុំសូមអញ្ជើញអ្នកអានឲ្យទៅសិក្សាលើការស្រាវជ្រាវយ៉ាងល្បោះល្បាយមួយដែលលោកស្រីបណ្ឌិត ពៅ សាវរស បានធ្វើការស្រាវជ្រាវរួចហើយ និងបានចុះផ្សាយឲ្យដំណឹងក្នុងកំណត់មួយដែលបោះពុម្ពនៅឆ្នាំ១៩៧៥ (J.A, 1975, p. 119-24), ហើយដែលយើងខ្ញុំសូមរំឭកម្ដងទៀតខ្លះដូចតទៅនេះ គឺ : ឯក (Ek), បញ្ច (pañc), ចត (cat), ទោ (do), គឺ ១៥៤២ ស័ក ឆ្នាំវកនក្សត្រ, ត្រូវនិងគ.ស.១៦២០ ។

លោកស្រីបានល្បងជាពិសេសរហូតដល់បានជោគជ័យគឺ បំបែករកថ្ងៃខែដែលតម្រួតបង្កប់គ្នានៅក្នុងបុព្វកថានៃចំណាររនោះគឺ ១៥៤២ស័ក, ត្រូវនិងគ្រិស្តសករាជ១៦២០ ។ លោកស្រី បានជូនពត៌មានក្នុងវគ្គពិសេសនៃអង្គការមួយឈ្មោះថា : សូស៊ីយ៉េតេ អាស៊ីយ៉ាទិក (Société Asiatique) ហើយអង្គការនេះក៏រៀបចំបោះពុម្ពក្នុងព្រឹត្តិប័ត្រ "ហ្សួកណាល់ អាស៊ីយ៉ាទិក" (Journal Asiatique) ដោយចុះចំណងជើងថា : "កំណត់នៃការចុះថ្ងៃខែរបស់ល្បើកអង្គរវត្ត" (Note sur la date du Poème d'Angkor Vat, Journal Asiatique, t. CCLXIII, Fasc. 1-2, Paris 1975 : 119-24)

នៅកម្ពុជា តាំងតែពីឆ្នាំ១៩៧០ សហគមន៍អ្នកសិក្សាស្រាវជ្រាវអន្តរជាតិ បានចាត់ទុកសម័យសតវត្សទី១៧ថា ជាសតវត្សដែលមានពន្លឺ ដោយសារតាមរយៈអក្សរសាស្ត្រខ្មែរនៅខណៈនោះ : មានស្នាដៃបែកកំណាព្យសុភាសិត និងសិលាចារឹក (Silācārik) ជាច្រើន ។ ក៏ប៉ុន្តែ គេមើលឃើញ

ស្រពិចស្រពិលដល់សហគមន៍ខ្មែរនេះ ដែលចូលចិត្តនិភាទនៃព្រះពុទ្ធសាសនា ផ្នែកថេរវាទ ។ រីឯកាលពីដើមគេមានទំនៀមយ៉ាងខ្ជាប់ខ្ជួន តាមជួនគារបស់គេទៅលើឥទ្ធិពលនៃព្រះដទៃបើនិយាយឲ្យពិតទៅគឺ ព្រះក្នុងព្រហ្មញ្ញសាសនានេះតែម្តង ។ ទំនងដោយសារសហគមន៍ខ្មែរនេះ ពោកបាចបំបែកចំណោះរបស់គេក្នុងបំណងបង្កើតអ្វីៗផ្សេងទៀត ។ ដូច្នេះហើយ ទើបរឿងព្រេងនិទានល្បើកអង្គរវត្តដ៏ប្រណីតនេះ បានប្រសូតមានរូបរាងឡើងនៅប្រទេសកម្ពុជា ដោយមានមួយចំណែកផ្តាច់ចេញពីអច្ឆរិយទេពសម័យចាស់ ដែលមានប្រភពពីឥណ្ឌា ។ រឿងព្រេងដ៏ប្រណីតនេះបានខិតខំយ៉ាងខ្លាំង ពង្រីកខ្លួនឡើងតាមចលនាប្រវត្តិសាស្ត្រនាបច្ចុប្បន្ន, បន្ទាប់មកក៏បានខំដាំភ្ជាប់ខ្លួនទៅក្នុងវប្បធម៌ខ្មែរ ។

"ល្បើកនគរវត្ត" ជាស្នាដៃដ៏អស្ចារ្យដែលបន្ថែមពីនោះទៅទៀតមានថ្ងៃខែកាលប្បវត្តិច្បាស់ គឺ ១៥៤២ស័ក (គ.ស. ១៦២០) (សូមអានក្នុងអត្ថបទនេះ) ។

សម័យរឿងល្បើកអង្គរវត្ត ជាសម័យក្រោយ "រឿងរាមកេរតិ៍" បន្តិចមកហើយ ។ រីឯរឿងរាមកេរ្តិ៍ ជារឿងដែលមានទំហឹធំជាង ហើយលើសពីនោះទៅទៀតគឺ រឿងរាមកេរតិ៍នោះ មានលក្ខណៈជារឿងវប្បធម៌ជាតិផង ។

តទៅនេះ យើងខ្ញុំនឹងសុំបើកឆាកបង្ហាញប្រធាន រឿងល្បើកអង្គរវត្ត :

-អង្គរវត្ត ជាទីបូរីដែលសាងដោយស្នាដៃវិចិត្រនៃស្ថាបត្យករ "ព្រះវិស្ណុការ" តាមបញ្ជារបស់ព្រះឥន្ទ្រ ដើម្បីថ្វាយដល់ស្តេចមួយព្រះអង្គជាក្សត្រិយ៍ក្នុងប្រវត្តិរឿងព្រេងគឺ "ព្រះកេតុមាលា" ។

## ៦. កំណាព្យ និង ស្នាដៃរបស់កវី

៦.១ តាមឯកសារនៅសេចក្តីផ្តើម៤វគ្គ អ្នកកវីពុំបានបញ្ជាក់អំពីឈ្មោះបទដែលលោក និពន្ធនោះទេ ។ យើងខ្ញុំពិនិត្យពិច័យមើលទៅឃើញជា "បទកាកគតិ" [22] តាមកំណត់ចាប់ចុង ចួន ។

៦.២ ចាប់ពីវគ្គទី៤ទៅ លោកបានបញ្ជាក់អំពីឈ្មោះបទ គឺ "បទព្រហ្មគិត" [23] មានទាំងអស់ ៨២វគ្គ ។

៦.៣ រីឯ "បទកាកគតិ" [24] មានទាំងអស់ ៩៨វគ្គ ។

22 Roeské, M., Métrique khmère, Bat et Kalabat, Anthropos, VIII, 1913.
23 Roeské, M., Métrique khmère, Bat et Kalabat, Ibid.



៦.៤ និពន្ធជា "បទពំនោល" [25] មានច្រើនវគ្គ រហូតដល់ទាំងអស់មាន ៣៦៥វគ្គ ។

៦.៥ ចំណែកឯសេចក្តីបញ្ចប់២វគ្គ ក៏អ្នកកវីពុំបានបញ្ជាក់អំពីឈ្មោះបទដែរ ដែលយើងខ្ញុំពិនិត្យពិច័យមើលទៅគឺជា "បទព្រហ្មគិត" តាមកំណត់ចាប់ចុងចួនដែរ ។

ដូច្នេះ ជាសារុបទៅអត្ថបទស្នាដៃរបស់គាត់មានទាំងអស់ ៥៤៥វគ្គ ។ ពិតមែនហើយថាការចាប់ចុងចួនខ្លះពុំបានល្អសព្វគ្រប់ក្តី តែភាគច្រើនបានត្រឹមត្រូវហើយប្រសើរប្រពៃផង ។

គួរឲ្យកត់សម្គាល់ដែរថា តាំងពីឆ្នាំ១៦២០ គឺឆ្នាំដែលកវី ប៉ាង ខាត បាននិពន្ធរឿងនេះ រហូតមកដល់សម័យបច្ចុប្បន្នគឺ ក្នុងអំឡុង៣៨៧ឆ្នាំ (ជិតបួនសតវត្ស) បន្តមកនេះ ក្នុងអក្សរសាស្ត្រខ្មែរលោកកវី-និពន្ធនានា គាត់បានបង្កើនបទថ្មីៗបន្ថែមទៀត ដើម្បីសេចក្តីត្រូវការក្នុងការនិពន្ធកំណាព្យផ្សេងៗ (សូមអានកំណត់ឯកសារលេខ២៤ក្នុងអត្ថបទនេះ) ។ សញ្ញានេះបញ្ជាក់ឲ្យឃើញថា ការដុះដាល សាយភាយ រីកចំរើន និងមានជីវិតរស់រវើកនៃអក្សរសាស្ត្រខ្មែរ ។ ឧទាហរណ៍ : "បទកង្កែបលោតកណ្តាលស្រះ", "បទសារថីទាញរថទី១", "បទនាគប្រែងឫទ្ធិ"... ជាស្នាដៃពិសេសរបស់ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ។ល។ ប៉ុន្តែ តាមការកត់សម្គាល់របស់យើងខ្ញុំ អស់លោកអ្នកកវីសម័យបច្ចុប្បន្នពុំសូវបានរាប់បញ្ចូលបទ ទាំងនោះទៅក្នុងស្នូនកំណាព្យរបស់គាត់ទេ ជាកត្តាមួយគួរឲ្យសោកស្តាយយ៉ាងខ្លាំង ។

ចំណងជើងល្បើកអង្គរវត្ត ដូចជាទន់ភ្ញន់ណាស់ យើងខ្ញុំទុកឲ្យឮសូរស័ព្ទបន្តទៅទៀត ដោយសារស័ព្ទនេះឮផ្ទែកបន្តិច តាមច្បាប់ដើមនៃអ្នកនិពន្ធ ។ ស័ព្ទនេះមានអត្ថន័យច្រើនមកពីពាក្យ "ល្បើក" ។ តាមលក្ខណៈនៃការបំបែកពាក្យ គឺពាក្យនេះមានឫសគល់ពីពាក្យ "លើក" ហើយពាក្យលើកមានន័យច្រើនទៀតយ៉ាងប្រសើរណាស់ផង :

-លើក (lever), ចិញ្ចឹម (élever), ទ្រទ្រង់ (soulever), យឹតយោង, បញ្ជើត (surélever), បរបាញ់, នេសាទ (lever le gibier, lever la nasse), គិតជញ្ជឹង (imaginer), សរសើរ, លើកដម្កើង (magnifier),

-សង់ (construire), សាង (bâtir), បង្កើត, ស្ថាបនា (édifier),

-និពន្ធ, សាងស្នាដៃអ្វីមួយ (concevoir un œuvre), ចងក្រងរឿងមួយ, តែងកំណាព្យ (composer

24 អៀង សាយ, មេកាព្យ, បណ្ណាគារ ម៉ី សុខ, ភ្នំពេញ ព.ស.២៥០៩, គ.ស.១៩៦៦ ។
25 អៀង សាយ, មេកាព្យ, បណ្ណាគារ និង ឆ្នាំបោះពុម្ពដ៏ដែល ។

un récit, un poème), រចនាគម្រូគម្រោងមួយ (créer des modèles), ប្រឌិត... ។ល។

បើតាមគំនិតនេះ និងតាមផ្នត់ដែក (infix) ២៦ អ្នកសិក្សាអាចបំបែកពាក្យឲ្យទៅជា “លើក” ឬ ចលនានៃ “លើក” បន្ទាប់ទៅនេះ ដែលគេជួបប្រទះជាញឹកញយ :

-ចលនានៃការ “លើក” ឡើង (fait d'élever), យីកយោង (surélever) ។ សរសើរ (éloge), លើកដម្កើង (gloirification), ។ លើកអន្ទាក់សត្វ, ប្រមាញ់ (rabatteurs de gibiers), ។

-ស្ថាបនា (édification) ។

-និពន្ធ, តែង, រៀបរៀង (រឿងព្រេងនិងព្រេងនិទាន, កំណាព្យ, សម្រាយ, ប្រវត្តិរឿងព្រេង, (conte, poème, fable, légende) ។ បើនិយាយអំពីសំពត់វិញ គេសំដៅថា “លើក” ដែរ “លើកគោម” ត្បាញ ។

វីលោកកវីយើងវិញ, គាត់ជាអ្នកនិពន្ធនោះ គាត់បានជ្រើសរើសពាក្យល្បើក ដែលមានអត្ថន័យទូលំទូលាយសម្រាប់ដាក់ “ចំណងជើង” នៃកំណាព្យរបស់គាត់ ។ បានន័យថាជា “កំណាព្យ” ប្រយោជន៍សូត្រលើកដម្កើង, សូត្រអំពីការស្ថាបនា ឬ សូត្រអំពីរឿងព្រេង ។

កំណាព្យនោះចែកជាជំពូកធម្មតាមាន ៣ជំពូក :

ក-សេចក្តីផ្តើម (វគ្គទី១ ដល់ ២៣)

ខ-អង្គសេចក្តី (វគ្គ២៤ ដល់ ៩៤៣)

គ-ការរំលឹកខាងចុងបង្អស់ ២វគ្គ និយាយឲ្យងាយថា “វគ្គបញ្ចប់” (ចប់, Cap' ou fin) ។ ការចងក្រងឡើងជា “បទ” (pad) សាមញ្ញ គឺកាកគតិ (Kākagati), ព្រហ្មគីតិ (Brahmagīti) និងពំនោល (Baṃnol) ។ បទនិមួយៗ មានការផ្លាស់ប្តូរតាមផ្នត់រឿង (តាមវគ្គ) គឺជាសាមញ្ញ ធម្មតាដែរ តែបទពំនោលឃើញមានច្រើនវគ្គជាងគេ ការនេះជាការត្រឹមត្រូវ ពីព្រោះពាក្យនេះបានអត្ថន័យ ថាកិច្ចប្រកាសឡើង, ការរៀបរាប់ (Narrer), សេចក្តីប្រកាសឡើង (សេចក្តីបន្ទឺឡើង, déclamer) ។

26 Voir LEWITZ, Saveros, «The Infix /-b/ in khmer», Austroasiatic Studies, Honolulu, II, 1976 : 741-60.



## ៧. និមិត្តរូបអង្គរនាសម័យកណ្តាល (ស.វ.ទី១៤ ដល់ ស.វ.១៨)

តាមសិលាចារឹកសម័យក្រោយអង្គរ (ស.វ.ទី១៤ ដល់ ស.វ.ទី១៨) ជាភាសាខ្មែរកណ្តាល ដែលត្រូវរកឃើញឡើង ពីគ្រប់ទីសទីនៃប្រទេសកម្ពុជា ភាគច្រើនដែលប្រសើរប្រណីតនោះ បានរំឭកឡើងតែអំពីបូជនីយដ្ឋានតំបន់អង្គរ ។ សិលាចារឹកទាំងនោះ មានចុះថ្ងៃខែ មានពីស.វ.ទី១៤ ដល់ ស.វ.ទី១៩ និង និពន្ធឡើងជា អត្ថបទរំឭកអំពីសាសនា (textes votifs) ដែលមានជាអាទិ៍គឺ លទ្ធិថេរវាទ ដែលយើងខ្ញុំបានប្រើពាក្យថា “សត្យាប្រណិធាន” (satyparaṇidhān) ។

លក្ខណៈទីពីរ ដែលសំខាន់នៅទីនេះដែរគឺ ប្រធាន “សំពះ” (Sambaḥ, pèlerinage) គឺក្នុងន័យបំពេញ “បុណ្យ” (actes de mérites, puṇy) ។

លក្ខណៈទីបី គឺបូជនីយដ្ឋានអង្គរនេះ ជាទីបំពេញបុណ្យ និង អំពើដ៏ល្អប្រសើរនៃប្រជារាស្ត្រ គឺថា តាំងពីសម័យដើមមកបូជនីយសក៏ទាំងនោះ តែងតែបានទទួលប្រជារាស្ត្រពុំដែលអាក់ខានទេ គឺគេនៅតែបំពេញកិច្ចគោរពបូជា រហូតរៀងមកគ្រប់ៗសតវត្ស ។

បន្ទាប់មកមានសិលាចារឹកតូចតាចទៀតនៅអង្គរ ដែលគេហៅថា “ចារខ្សៀក” (graffitti) ឥតបានចុះថ្ងៃខែទេ តែគេអាចគិតរយៈកាលដែលចារបាន គឺក្នុងស.វទី១៨ ។

មានសិលាចារឹកមួយផ្សេងទៀត ដែលគេទើបតែរកឃើញក្នុងបញ្ជីនៃក្រដាសប្រថាប់របស់សាលាបារាំងនៃចុងបូព៌ា (Ecole Française d'Extrême-Orient, E.F.E.O.) មានចុះថ្ងៃខែយ៉ាងច្បាស់គឺ : ពុទ្ធសករាជ២៤២៥ ឬ គ្រិស្តសករាជ១៨៨១ ដោយបានរកឃើញដប់ម្ភៃឆ្នាំមកហើយ នៅតំបន់បូជនីយដ្ឋានអង្គរធំ ។ សិលាចារឹកនោះបានឲ្យដឹងថា មានបូជនីយសក៏ពីរនាក់មក ពីរាជធានីភ្នំពេញបានជួបអ្នកដទៃ ដែលមកពីគ្រប់ខេត្តខ័ណ្ឌនៃកម្ពុជា ក្នុងគោលបំណងដូចគ្នាគឺ “មានជំនឿលើព្រះ និង គោរពព្រះ” ។

សិលាចារឹកទាំងនោះ ជាសក្ខីភាពបញ្ជាក់ឲ្យយើងបានដឹងម្យ៉ាងគឺអង្គរជារៀងរាល់ពេលទាំងអស់ជា “ព្រះនគរ” ឬជា “ព្រះអង្គរ” ឬ លើសពីនេះទៀតជា “ព្រះមហានគរ” (La grande cité sacrée) ។ សំណាដែលសរសេរយ៉ាងច្រើនជួយបញ្ជាក់ច្បាស់លាស់ប្រាកដ និងយ៉ាងសំខាន់ គឺក្រុមប្រភេទសិលាចារឹកនេះតែម្តង ។

អង្គរក្នុងសម័យចាស់មាននាមថា “យសោធរបុរៈ” (ជោគជ័យ, la gloirieurse) ដែល

ជាស្នាព្រះហស្តនៃព្រះមហាក្សត្រិយ៍ ព្រះនាមថា ព្រះបាទយសោវរ្ម័ទី១ ។ ទីក្រុងនេះ បានត្រូវ កវី-បណ្ឌិត សម័យនោះស្គាល់យ៉ាងច្បាស់លាស់តាមពាក្យខ្មែរ និងបំព្រួញខ្ទីពីពាក្យមួយទៅពាក្យមួយ គឺ : មហានគរ ហៅទៅជា ស្រីសុធរ (Srī Sudhar) ក្នុងសិលាចារឹកទំនើបនៃអង្គរវត្ត (IMA 16, B : 20) ។ អ្នកប្រវត្តិសាស្ត្រយើងមុន ក្នុងខណៈនោះ មានលោកសឺដេស ហ្សក (Cœdès George) បន្ទាប់មក គ្រោស្លីយេ បែរណា-ហ្វីលីព្ព (Groslier Bernard Philppe) បានអនុមត្តិពេញសិទ្ធិត្រឹមត្រូវថា នាមនៃក្រុងនេះ បានត្រូវព្រះមហាក្សត្រិយ៍សម័យក្រោយអង្គរ យកមកប្រតិស្ឋនាមនៃរាជធានីសម័យកណ្តាល នៅភាគខាងត្បូងវិញ : "ស្រីសុធរ" ឬ "ស្រីសន្ធរ" ។

ប៉ុន្តែ នាមប្រាកដនៃបុរីនេះពុំអាចកែប្រែបានគឺ "ឥន្ទ្រប្រស្ថ" ពីព្រោះគេប្រទះឃើញនៅលើអក្សរសរសេរក្នុងការនិពន្ធអក្សរសាស្ត្រ ឬការនិពន្ធច្បាប់-ក្រឹត្យផ្សេងៗ (សូមរំឭកថាព្រះបាទអង្គឌួង ក៏បានបញ្ញត្តឲ្យគេបោះពុម្ពលើប្រាក់ឈ្មោះរាជធានីនេះក្នុងរាជ្យព្រះអង្គ ហើយរយៈពេលនោះគ្រាន់តែសរសេរទៅជាឥន្ទ្របត្ថវិញ ជាភាសាបាលី) ។

ក្រោយពីនោះ យើងខ្ញុំសូមរំឭកថា លោកស្រីបណ្ឌិតពៅ សាវរស បានចំណាយពេលយ៉ាងសន្ធឹកសន្ធាប់ដើម្បីពិចារណា និងបានអនុមត្តិយកនាមដែលអតីតព្រះមហាក្សត្រិយ៍បានប្រសិទ្ធិនាមឲ្យទីក្រុងដែលបានស្ថាបនាក្រោយសម័យអង្គរ [27] ។

ឥន្ទ្រប្រស្ថ ជានាមបុរីមួយក្នុងចំណោមនាមបុរីផ្សេងៗ ក្នុងរឿងមហាភារត ដែលជារឿងដែលខ្មែរស្គាល់យ៉ាងច្បាស់ក្នុងសម័យចាស់បើតាមគេដឹង ។ ពីព្រោះ គេប្រទះឃើញមានចារក្នុងសិលាចារឹកនូវនាមឋាននេះ ។ ក្រោយមករឿងមហាភារតនេះត្រូវរលុបរលាយពីវិញ្ញាណ ពីការនិពន្ធនៃកវី-បណ្ឌិត និង អំពីសិល្បៈនាសម័យកណ្តាលនៅកម្ពុជា ។ ជាការពិតហើយ គឺនាមទាំងនេះត្រូវបានបង្កប់យ៉ាងជ្រៅនៅក្នុងអារម្មណ៍ទាំងអស់គ្នា ទាំងក្នុងសង្គម ។

ក្នុងសាវតារវត្តសម្បុក ១៥២៣ស័ក ឬ គ.ស.១៦០១ ព្រះនគរត្រូវគេហៅឈ្មោះថា : "ស្រីឥន្ទ្រប្រត្ថ គុរុរដ្ឋ" (ជោគជ័យនៃឥន្ទ្រប្រស្ថ នៅគុរុក្សេត្រ, Le glorieux indraprașthа du Kurukșetra) បរិយាយអំពីនាមយ៉ាងជាក់ច្បាស់ ។

27 [ពៅ សាវរស, មុខបាឋៈ (ការសិក្សាផ្ទាល់ និងការសន្ទនាជាមួយគ្រូ), ថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៩៨] ។



-ប្រការទីពីរទៀត ពពួក "សិលាចារឹកទំនើប សម័យស.វ.ទី១៦ ដល់ ស.វ.ទី១៨ នៅអង្គរបានឲ្យឈ្មោះ បុរីនេះដូចគ្នាថា : ឥន្ទ្រប្រស្ថ / ឥន្ទ្របត្ថ, (Indraprașth / Indrapath) ។ បានន័យថា "ឋានព្រះឥន្ទ្រ" [28] (ប្រាកដហើយកាលៈទេសៈនៃវីរភាពដែលបានបញ្ជាក់នៅក្នុងសាវតារ ពុំបានប្រើទូទៅទេ ដែលឲ្យគេជឿថា នាមនៃក្រុងនោះបានប្រើប្រាស់ទូទាំងប្រទេស) ។ បើសិនជាពេលនេះ មានសហគមន៍ណាចង់និពន្ធឡើងវិញនូវប្រវត្តិនៃមហានគរ គេអាចហៅបុរី ដែលមានឈ្មោះថា ជាស្ថាននៃព្រះឥន្ទ្រនោះក៏បានគ្មានអ្វី ដែលអាចឃាត់ឃាំងមិនឲ្យហៅក្រុងនោះថា "ឥន្ទ្រប្រស្ថ" នោះទេ (សូមអានវគ្គទី១៣៧ក្នុងកំណាព្យ) ។ ពីព្រោះ បុរីនេះមានអត្ថន័យយ៉ាងល្អ អាចក្រសោបត្រឹមត្រូវជាមួយរឿងព្រេង "ស្ថានព្រះឥន្ទ្រ" គឺល្បើកអង្គរវត្ត ។

ម្យ៉ាងវិញទៀត មានស្នាដៃខ្លះនៃពុទ្ធសាសនិកបានកែពាក្យជាភាសា "បាលី" ដើមប្រើក្នុងខណៈនោះថា "ឥន្ទបត្ថ" បើតាមឯកសាររបស់យើងខ្ញុំវិញ ពាក្យបាលីអាចគ្របដណ្តប់ទៅលើពាក្យសំស្រ្កឹត យ៉ាងងាយរហ័ស ពីព្រោះ "ស័ព្ទ" ក្នុងភាសាបាលីអាចជិតដិត និងស័ព្ទនៃភាសាខ្មែរ (សូមអានក្នុងវគ្គនេះផង) ។

ទោះបីម្តេចម្តាក្តី រាជធានីចាស់នៅតែបន្តជីវិតរស់រវើក សូម្បីតែមានឈ្មោះមួយផ្សេងទៀតក៏មែនពិត ប៉ុន្តែ កំរិតចាប់អារម្មណ៍ និងការនឹកភ្នានៃសង្គមខ្មែរនៅមានជានិច្ច ។ គឺដោយសារអារម្មណ៍ និករឭកសម័យឥន្ទ្រប្រស្ថ ឬ ឥន្ទ្របត្ថ នោះនៅនាចុងស.វ.ទី១៥ និងដើម ស.វ.ទី១៦ រៀងមកនោះហើយ ទើបនៅស.វ.ទី១៧ កវី ប៉ាង តាត យើងគាត់ក៏ចាប់កត់ត្រា ឈ្មោះរាជធានី និងនិពន្ធកំណាព្យរឿងព្រេងនោះ (សូមអញ្ជើញអានអត្ថបទ) ។ បន្ទាប់មកទៀត នៅក្នុងស.វ.ទី១៨ មានបូជនីយេសក៏ម្នាក់ (អ្នកទៅថ្វាយបង្គំព្រះ) មានបំណងចង់ចារពណ៌នារឿងនិទាននេះឡើងនៅនិងប្រាសាទ តែពុំបានសម្រេចតាមបំណងទៅវិញ ដោយពុំដឹងពិតអំពីមូលហេតុអ្វីឡើយ ។ ហើយតាមការចារខ្សៀកបន្តិចនោះគេអាចអានបានឈ្មោះនោះថា "មហាឥន្ទ្របថ" (IMA 40 / K. 302, dans NIC III, p. 268) ។

ក្រោយពីការសិក្សាអំពីនាមបុរីព្រះនគរនេះមក យើងខ្ញុំសូមសង្រួមស្មារតីទៅលើ "អង្គរវត្ត"

28 យោងតាមនាម បុរីអង្គរ ដែលហៅថា ឥន្ទ្រប្រស្ថ ? ឥន្ទ្របត្ថ នេះហើយ ទើបអ្នកនិពន្ធយើងបានចាត់ព្រះមហាក្សត្រិយ៍ថា ជាព្រះឥន្ទ្រ ឬ ជាបុត្រព្រះឥន្ទ្រដែរ, ហើយក៏ចាត់ទុកអគ្គវិស្វករថា ជាព្រះវិស្វកម្មទេវបុត្រ ឬ ព្រះវិស្ណុការ ដូចយើងបានឃើញក្នុងរឿងល្បើកអង្គរនេះស្រាប់ ។

ពីព្រោះជាប្រធានសំខាន់នៃកំណាព្យ ហើយយើងខ្ញុំសូមល្បងអានតាមឈ្មោះទាំងនោះ ដើម្បីវាយតម្លៃអត្ថន័យនៃបូរីអង្គរ ក្នុងអារម្មណ៍របស់យើងគ្រប់គ្នាក្នុងសហគមន៍នេះ ។

អង្គរវត្តជាឈ្មោះដែលរន្ទឺល្បីទូទៅ និងប្រើប្រាស់ច្រើន ប៉ុន្តែ ប្រជារាស្ត្រផ្ទាល់ខ្លះហៅ "អង្គរតូច", (petit Aṅgara) ព្រោះតូចជាងអង្គរធំ ។ ឈ្មោះនេះពុំមែនយោងទៅលើតូចតាច ស្តួចស្តើងឡើយ ប៉ុន្តែ ន័យសំដៅទៅលើកំពែងព័ទ្ធជុំវិញឯណោះទេ ។ រីឯខាងសម្ផស្ស បើប្រៀបផ្ទឹមទៅ និងប្រព័ន្ធប្រាសាទថ្លុងច្រាងនៃ "អង្គរធំ" ឃើញថា "អង្គរតូច" នេះមានទ្រង់ទ្រាយ : ហ្មត់ហ្មង, ល្អពិចិត្រ, សម្រិតសម្រាំង, សម្ផស្សប្រណីត, ប្រឡឹង, ទន់ភ្លន់... ដែលគេឯងស្គាល់ទាំងសាកលយ៉ាងប្រណីតគឺ "អង្គរវត្ត" បានជាហៅនាមថា អង្គរវត្ត ព្រោះមានសាងវត្តព្រះពុទ្ធសាសនានៅជិតជុំគ្នានិង "អង្គរ" ដែលជាព្រះវិហារនៃព្រហ្មញ្ញសាសនា គឺជា "ប្រាសាទ" [២៩] នោះឯង ។

បើតាមយើងខ្ញុំដឹង មានតែឈ្មោះ "អង្គរវត្ត" ឬ "នគរវត្ត" នេះទេដែលយើងបានឃើញ គេបញ្ចេញច្រើនក្នុងកិច្ចការនិពន្ធនានា នៃកវី-អ្នកអក្សរសាស្ត្រ តែពាក្យ "អង្គរតូច" (Aṅgara Tūc) គ្មានដែលឃើញបញ្ចេញសោះទេ ។

អ្នកប្រាជ្ញអក្សរសាស្ត្រសម័យអង្គរ ឲ្យឈ្មោះប្រាសាទថា "ព្រះពិស្ណុលោក" (Braḥ Bisṇuloka) ឈ្មោះនេះ គេឃើញមានបញ្ចេញឡើងក្នុងសិលាចារឹក ដែលចារភ្ជាប់នៅនិងប្រាសាទនោះ ។ ឈ្មោះនេះហើយដែលគេប្រកាសឡើង នៅពេលដែលគេមកធ្វើបូជនិយេសន៍ ដើម្បីបំពេញបុណ្យកុសលម្តងៗ ។ គេឃើញច្បាស់នៅក្នុងសិលាចារឹកទំនើបនៅអង្គរ លេខពីរ (IMA. 2) ជាសិលាចារឹករបស់ព្រះបាទជ័យជេដ្ឋា បានបញ្ចេញឲ្យដឹងថា មានធ្វើបូជនីយេសិ៍ កីបំពេញបុណ្យហើយ "ព្រះអង្គបានផ្តើមធ្វើការផ្ទុសផុល" "ព្រះពិស្ណុលោក" ជាបូរាណប្រាសាទ នៃប្រទេសកម្ពុជាទៀតផង ដើម្បីឲ្យមានសណ្ឋានល្អពណ្ណរាយដូចពីអតីតកាល" [៣០] ។

ផ្សេងពីនោះទៀត មានព្រះនាមមួយទៀត ដែលពុំមែនចាត់ទុកថាជារឿងព្រេង ឬអច្ឆរិយឡើយ គឺជាព្រះនាមប្រវត្តិសាស្ត្រ ពីព្រោះមហាក្សត្រិយ៍ដែលបានស្ថាបនា "ប្រាសាទអង្គរវត្ត" គឺព្រះបាទសូរ្យវរ្ម័ទី២ ។ តាមជំនឿសាសនា ព្រះមហាក្សត្រិយ៍អង្គនេះ លុះទ្រង់សោយទីវង្គតទៅ "ព្រះអង្គទ្រង់យាងទៅកាន់ស្ថានព្រះវិស្ណុ"(au ciel de Viṣṇu) ឬ "វិស្ណុលោក" (Viṣṇuloka) ។ ព្រះបច្ឆាមរណនាមនេះ គេបានឃើញបញ្ចេញឡើងនៅក្នុងសិលាចារឹក ហើយមានការផ្លាស់ប្តូរខ្លះ តែពុំមានអ្វីគួរឲ្យយកចិត្តនោះទេ រវាងពាក្យ "បរមវិស្ណុលោក" ឬមហាវិស្ណុលោក (Paramaviṣṇuloka ou Mohaviṣṇuloka) ។ ព្រះបច្ឆាមរណនាមខាងដើមនេះ បានបញ្ចេញឲ្យឃើញតាមរយៈសិលាចារឹកពីរដែលចារនៅទន្ទឹម និងចម្លាក់ក្រឡោតភ្ជាប់ជញ្ជាំងប្រាសាទនាសតវត្សទី១៦ ។ ប្រាសាទអង្គរវត្តស្ថិតនៅល្អល្អះឥតខ្ចោះ ដែលកម្រមានក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា ទោះទាំងនៅតំបន់ផ្សេងៗទៀតក្តី ។

រហូតមកដល់សតវត្សទី១៦ នាមនៃប្រាសាទ គឺព្រះវិស្ណុលោក, បរមវិស្ណុលោក ឬមហាវិស្ណុលោក ដែលសាងដោយក្សត្រិយ៍អង្គរនេះបានក្លាយទៅជាព្រះនាមរបស់ទ្រង់ ហើយបានល្បីល្បាញជាលំដាប់លំដោយមក ។

នៅក្នុងសង្គម-វប្បធម៌របស់យើង មានព្រឹត្តិការណ៍មួយដទៃទៀតគឺ នៅកំឡុងពាក់កណ្តាលនៃសតវត្សទី១៦ បើតាមការពិតប្រវត្តិរឿងនិទានបានកកើតច្បាស់ស្រេចទៅហើយៗ ក៏បានមកតភ្ជាប់ជាមួយប្រវត្តិសាស្ត្រ ដើម្បីថ្លៃប្រវត្តិសាស្ត្រនេះ ឲ្យចូលទៅក្នុងការស្រមើស្រមៃរបស់ប្រជានុរាស្ត្រ ។

នៅសម័យកណ្តាល (ស.វ.ទី១៤ ដល់ ស.វ.ទី១៨) នៅប្រទេសកម្ពុជា គេសង្កេតឃើញមានគំនិតលើករឿងបញ្ចូលផ្សំនិងការលាយឡំគ្នានេះច្រើនណាស់ ។ បើគិតឲ្យដល់ជម្រៅទៅប្រវត្តិបែបនេះ គឺមានស្ថានភាពប្រហាក់ប្រហែលគ្នា ទៅនិងប្រវត្តិរឿងព្រេងនៃប្រទេសខ្លះទៀត ក្នុងពិភពលោកដែរ ។

អ្នកនិពន្ធ "សិលាចារឹកទំនើបនៅអង្គរវត្ត", (IMA.16) លេខ១៦ បាននិពន្ធទុកថា ការបំពេញបុណ្យបានប្រព្រឹត្តិឡើង ដោយមានបូជនីយេសក៏សន្ធឹកកុះករ ។ ការបំពេញបុណ្យបានធ្វើនៅក្នុងព្រះមហាបូរីឥន្ទ្រប្រស្ថស្រីសន្ធរដ៏ខ្ពង់ខ្ពស់នៃព្រះវិស្ណុ" [៣១] ។ មានឃ្លាដ៏ល្អមួយទៀតនៃសិលាចារឹកនោះចារថា "ព្រះវិស្ណុដ៏កំពូលនៃព្រះមហាបូរីឥន្ទ្រប្រស្ថ ស្រីយសោធរៈ" ។

ការយកនាមព្រះមហាក្សត្រិយ៍មកដាក់ឈ្មោះបូរីអង្គរនោះ មានតាំងតែពីកាល "ប្រសិទ្ធិនាម" ប្រាសាទកាលពីសម័យចាស់ម្ល៉េះ ។

29 [ពៅ សាវរស, មុខបាឋៈ, ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៥] ។
Pou, Saveros, «Les noms des Monuments khmers», *BEFEO*, t. LXXVIII, 1991 : 203-24.

30 Pou, Saveros, «Inscriptions Modernes d'Angkor», IMA.2, *BEFEO*, t. LVII, Paris 1970 : 103.

31. Pou, Saveros, «Inscriptions Modernes d'Angkor», IMA.16, *BEFEO* t. LIX, Paris 1971.

ការប្រសិទ្ធិនាមបានត្រូវរាយបន្តបន្ទាប់មក តាមរឿងនិទានដោយលាយឡំពីនាមមួយទៅនាមមួយទៀត : ស្ថាបត្យករមួយអង្គ មាននាមថា "វិស្វកម្ម" ដែលត្រូវបានព្រះឥន្ទ្របញ្ជូនឲ្យមកស្ថានមនុស្សលោកនេះ ដើម្បីមកធ្វើមេបញ្ជាការនៃសំណង់ ។ យើងខ្ញុំសង្កេតឃើញថា ព្រះនាមនោះត្រូវប្តូរទៅវិញថា "ព្រះពិស្ណុការ" (Braḥ Bisṇukār) ។ ព្រះនាមដូច្នេះ អ្នកស្រុកហៅលាយឡំថា "ព្រះពិស្ណុការ" ។ វិស្វកររបស់ព្រះឥន្ទ្រនោះទៅ ជាមួយព្រះបច្ឆាមរណនាមនៃព្រះមហាក្សត្រិយ៍ដែល ព្រះអង្គទ្រង់បានសាងប្រាសាទ "ព្រះវិស្ណុលោក" ។ ក្រោយមកព្រះនាមនេះ គេឃើញមានចារបញ្ចេញឡើងនៅក្នុងសិលាចារឹកខ្មែរ នៅឯក្រុងសុខោទ័យ (Sukhoday) នាសតវត្សទី១៤ តែនៅសម័យនោះ បូរីអង្គរនៅត្រឹមត្រដែតនៅឡើយ (នៅស្រុកសៀមសព្វថ្ងៃមានខែត្រមួយឈ្មោះខែត្រពិស្ណុលោក) ។ យើងបានសំគាល់ឃើញថា ប្រវត្តិផ្សេងៗ បានខ្ទុកដោយអច្ឆរិយដោយងាយៗពេកណាស់ ។ ដូច្នេះ យើងសូមវិភាគដូចតទៅ : ព្រះមហាក្សត្រិយ៍សូរ្យវម៌្មទី២ បានបំពេញសកម្មភាព, បានសាងស្ថាបត្យកម្មរបស់ទ្រង់ គឺ "ប្រាសាទអង្គរវត្ត" ឬអាចហៅម្យ៉ាងទៀតថា "ព្រះកិរតិ, សំស្រ្កឹត, (ខ្មែរចាស់, ខ្មែរទំនើប "កេរតិ៍=កេរ្តិ៍") ។

ក្រោយពី "ព្រះអង្គទ្រង់យាងទៅកាន់ស្ថានព្រះវិស្ណុ" (rejoint le monde de Viṣṇu), ប្រជារាស្ត្រខ្មែរបត់ផ្លូវកែងយ៉ាងងាយ ដោយមានលំអានស្រាប់ផង អំពីស្ថាបត្យកម្មដែលមានបញ្ជាពីព្រះឥន្ទ្រ ហើយសាងឡើងដោយស្ថាបត្យករនៃព្រះឥន្ទ្រ គឺព្រះវិស្វកម្មទេវបុត្រ ដែលខ្មែរបានសម្រួលព្រះនាមថា "ព្រះពិស្ណុការ" ដើម្បីឲ្យបានសមស្របជាមួយព្រះបច្ឆាមរណនាមនៃព្រះមហាក្សត្រិយ៍ ។ តើមានអ្វីទៀត ដែលសម្របតាមធម្មជាតិក្នុងការធ្វើឲ្យស្រមើស្រម៉ៃក្នុងបំណងភ្ជាប់ ព្រះមហាក្សត្រិយ៍ទៅជាទេព ដូចប្រជារាស្ត្រខ្មែរមានបំណងនេះ [៣២] ។

ការបញ្ចូលឲ្យទៅជារបស់មួយ (រូបតែមួយ) វិស្ណុលោក ពិស្ណុការ (Viṣṇu Bisṇukār) បង្កើតឡើងដោយបញ្ញាមនុស្សដែលគេមានបំណងយ៉ាងខ្លាំងចំពោះអច្ឆរិយវត្ថុឲ្យទៅជាព្រះទេពទាំងឡាយ ក្រោយពីមរណភាពនៃមនុស្សនោះ នេះជាព្រឹត្តិការណ៍វប្បធម៌ជាក់ស្តែង និងមានតែក្នុងសង្គមខ្មែរសម័យចាស់ ។ ការបញ្ចូលផ្សំប្រភេទ នេះបានបង្ហាញឲ្យមានជាសក្ខីភាពសម្បូរ និង ត្រេកត្រអាលយ៉ាងខ្លាំងអាចទាញយកឱកាសបានគ្រប់ពេលទាំងអស់ ។ ផ្ទុយវិញទៀត ទោះទាំងសហគមន៍ដទៃក៏មានការឆក់ឱកាសដូចគ្នា ។

32. [ពៅ សាវរស, មុខបាឋ:, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០] ។



ការធ្លាក់ចុះដុនដាបនៃព្រះនគរនាសតវត្សបន្ទាប់មក ជម្រុញឲ្យមានការច្របូកច្របល់កាន់តែខ្លាំងបង្កើតការរិះគិតប្រឌិត "រឿងព្រេងល្បើកអង្គរវត្ត" ហើយបានពន្រាយពាសពេញដោយនិយាយតៗគ្នាមុនពេលនិពន្ធឡើងជាសំណេរទៅទៀត ។ នៅសតវត្សទី១៧ គឺនៅអង្គរនោះហើយ ដែលជាកន្លែងនិពន្ធឡើងនូវរឿង "ល្បើកអង្គរវត្ត" ។ ល្បើកអង្គរនេះ ដូចយើងបានប្រទះឃើញពីខាងលើហើយថា ល្បើកនេះកើតឡើង ដើម្បីសូត្រសរសើរដល់ជោគជ័យនៃប្រាសាទ ។ នៅសម័យនោះបូជនីយសក៏បានមកកាន់ទីនេះយ៉ាងគគ្រឹក គគ្រេងនៅបរិវេណអង្គរ, បានមកពីទីជិតទីឆ្ងាយក្នុងបំណងមកធ្វើបុណ្យគោរពព្រះពុទ្ធសាសនានិកាយថេរវាទ ។ មានអ្នកបំពេញបុណ្យខ្លះទៀត ឆ្លៀតចារនៅលើថ្មអង្គរនូវប្រវត្តិខ្លីៗ សំខាន់ៗនៃការធ្វើបុណ្យនេះ ។ សំណាដៃជាអត្ថបទសិលាចារឹកទំនើបអង្គរវត្តនេះ (IMA), សម្រាប់ជាប្រវត្តិសាស្ត្រប្រត្យក្សដល់មនុស្សជាតិទាំងអស់ ។ បូជនីយសក៏ទាំងនោះពុំមែនប្រាថ្នាចារទុកជាអក្សរសាស្ត្រ ឬ សិល្បៈឡើយ គោលបំណងតែមួយគត់ដែលយើងត្រូវចងចាំ និងដឹងគឺ "សទ្ធា" (la foi) ។ សទ្ធា (Saddhā) នេះហើយ ដែលតម្រូវឲ្យបូជនីយសក៏ទាំងអស់មកបញ្ចេញនូវសច្ចៈ (Satya, sacca, la vérité) ។ ប៉ុន្តែ ភាពឧត្តុង្គឧត្តម និងជ័យជោគរបស់អង្គរពុំអាចទប់ស្កាត់នូវការថ្លែងសរសើរបញ្ចេញស្នេហ៍ កំណាព្យនូវការរំជើបរំជួលគោរពដល់ព្រះនគរដ៏ប្រសើរនេះបានឡើយ ។

សិលាចារឹកទំនើបអង្គរ លេខ២ (IMA.2) បានអត្ថាធិប្បាយយ៉ាងច្បាស់អំពីការបំពេញបុណ្យរបស់ព្រះមហាក្សត្រិយ៍ជ័យជេដ្ឋា (ជេដ្ឋា) : *ព្រះពិស្ណុលោក ឝ ជា ស្ថាន ជំនុំ នៃទេវតា មហាក្សត្រ មហាព្រហ្មឫសី សិទ្ធសក្តិ នុ ទេពរក្ស បិត្រគណៈ ផោង ស្បង គ ជំនុំ សមុគ្គតា,* បានន័យថា "ព្រះពិស្ណុលោក គឺជាកន្លែងស្ថានប្រជុំអស់ទាំងព្រះអទិទេព, ព្រះដ៏ធំនៃព្រហ្មញ្ញសាសនា, ព្រះមហាឫស្សីខាងព្រហ្មញ្ញសាសនាដែលពោរពេញដោយតេជះ, ព្រះអ្នករក្សាទឹកដី និងក្រុមព្រះឯទៀតមកប្រជុំសភានៅទីនេះ" [៣៣] ។

សេចក្តីប្រកាសឡើងផ្ទួនៗ នេះជាសក្ខីភាពបញ្ជាក់ឲ្យឃើញថា ប្រាសាទអង្គរស្ថិតនៅក្នុងអារម្មណ៍របស់ខ្មែរ តាំងពីសម័យបុរាណកាលមក ។ ក្នុងបរិវេណអង្គរមានព្រះវិហារពុទ្ធសាសនា វត្តអារាមដែលមានព្រះភិក្ខុសង្ឃគង់នៅ បើកឲ្យអ្នកខ្មែរធ្វើបុណ្យឧទិសកុសល នឹកដល់ព្រះពុទ្ធសក្យ

33 Pou, Saveros, op. cit, *BEFEO*, t. LVII, Paris 1970 : 103.

មុនីទៀតផង ។ ប្រាសាទ ដែលជាកេរ្តិ៍អាករនៃសម័យអតីតកាលនោះ ឥឡូវនេះ ត្រូវបានទ្រទ្រង់រក្សាដោយពុទ្ធសាសនិកដោយហេតុថា : ប្រាសាទជាទីស្ថាននៃព្រះដទៃទៀតជាច្រើនផង (devatā) និងមានវត្តនៃព្រះពុទ្ធសាសនា ព្រមទាំងពពួកក្រុមទេវតាផង ជាពិសេសព្រះទាំង៤ក្រុមនេះ :

ក-ព្រះមហាក្សេត្រ, ជាពពួកព្រះដីធំមួយក្រុមក្នុងព្រហ្មញ្ញសាសនា ។ "ព្រះក្សេត្រ" ពាក្យដើមមកពីពាក្យ "សំស្ក្រឹត" បានន័យជា ពាក្យខ្មែរទំនើបថា "ចំការ, តំបន់" (Champs, régions) ។ ប៉ុន្តែពាក្យនេះមានអត្ថន័យមួយផ្សេងទៀត ដែលខ្មែរសម័យចាស់ស្គាល់ច្បាស់ជាក់លាក់ តែខ្មែរសម័យទំនើបលែងស្គាល់ព្រះនេះ ហើយឈប់គោរពបូជាទៀតផង ។ ក្នុងខណៈនោះជា "ព្រះក្នុងព្រហ្មញ្ញសាសនា" (Dieux brahmaniques) ដែលនៅរួមជាមួយ "ព្រះបញ្ចក្សេត្រ" គឺជាព្រះទាំង៥ ក្នុងព្រហ្មញ្ញសាសនា ។ ព្រះគ្រប់អង្គនេះត្រូវខ្មែររក្សាទុកក្នុងព្រះបរមរាជវាំង ។

ខ-ព្រះមហាព្រហ្មឫសី, ជាពពួកព្រះ មហាឫសីក្នុងព្រហ្មញ្ញសាសនា ។

គ-ព្រះទេពរក្ស (ទេព្រាក្ស), ជាពពួកក្រុមព្រះជួយរក្សាមនុស្សលោក ។

ឃ-ព្រះបិតរគណៈ, ជាពពួកក្រុមព្រះបិតរៈជួយរក្សាមនុស្សលោកដែរ (ពាក្យស័ព្ទទាំងនេះមានប្រើប្រាស់នៅសម័យខ្មែរចាស់ ហើយគេនៅតែស្គាល់ និងប្រើប្រាស់រហូតមកដល់សព្វថ្ងៃ ដូចពាក្យដែលបានពន្យល់មកហើយនេះ ទោះជាគេពុំបានកត់បញ្ចូលទៅក្នុងសទ្ទានុក្រមក្តី) ។ ពាក្យទាំងនេះ ប្រើយោងសំដៅទៅចំពោះពួកអច្ឆរិយទេពផ្សេង និងពពួកព្រាយបីសាច-ខ្មោច ដែលចូលរួមផ្ទុងតែមួយ ហើយ ស្ថិតនៅជួបជុំគ្នាក្នុងការជួយរក្សាមនុស្សម្នា ហើយជាទូទៅខ្មែរស្គាល់ និងគោរពបូជាផង ។

ពាក្យមួយផ្សេងទៀតដែលសំខាន់គឺ "បិតរៈ" (Pitara, Les ancêtres) ដែលខ្មែរ និងអ្នកអក្សរសាស្ត្រស្គាល់ប្រាកដ បានន័យថា "ឪពុក, ជីដូន-ជីតា" ដែលមានអត្ថន័យក្នុងជំនឿនៃពិធីផ្សេងៗ ហើយពាក្យនេះប្រើជារាជស័ព្ទថា ព្រះបិតរៈ (Brah Pitara, Les aïeux) ។ ទោះនៅក្នុងស្រទាប់សង្គមណាក៏ដោយ ជាការសំខាន់ណាស់ "ព្រះបិតរៈ" គឺជាទីគោរពដ៏ខ្ពង់ខ្ពស់ណាស់ បើពុំដូច្នោះទេ ខ្មោចជីដូនជីតាទាំងនោះ និងក្លាយទៅជា "ប្រេត" (Pret) ទៅវិញ ហើយតែងតែមកសុំទាន ឧបភោគបរិភោគពុំចេះចប់ និងមកធ្វើទុក្ខបុកម្នេញដល់មនុស្សលោកផង ។

អញ្ចឹងហើយ ទើបប្រាសាទអង្គរក្លាយទៅជាព្រះទេវស្ថាន នៃពុទ្ធសាសនិកនាសម័យកណ្តាលទៅវិញ (ស.វ.ទី១៦ ដល់ ស.វ.ទី១៩) ពីព្រោះប្រាសាទនេះ ជាទេវស្ថាន ជាជម្រកនៃអច្ឆរិយទេពនានា ដែលខ្មែរបានស្គាល់ពីសម័យអតីតកាលស្រាប់ផង ។



ឈ្មោះថា ល្បើកអង្គរវត្តអាចមានន័យថា "ការស្ថាបនាអង្គរវត្ត" ឬ "រឿងព្រេងនិទានអំពីអង្គរវត្ត" ដូចក្នុងទីនេះ ឬ "កំណាព្យអង្គរវត្ត" ។ ឬ ម្យ៉ាងទៀត ចំពោះអ្នកស្រាវជ្រាវដែលមានក្តីបារម្ភដើម្បីវិនិច្ឆ័យទៅតាមពាក្យស័ព្ទនោះ បានសេចក្តីថា "កំណាព្យអំពីប្រវត្តិនៃការស្ថាបនាអង្គរវត្ត" ។

នៅប្រទេសកម្ពុជា ខ្មែរជំនាន់មុនបានប្រសិទ្ធិនាម "ប្រាសាទបន្ទាយ" នេះ..., បន្ទាយនោះ... (Prāsād, pandāy) (Banteay) ពីព្រោះ ក្រោយសម័យមហានគរ ប្រាសាទទាំងឡាយអាចក្លាយទៅជា "ជម្រក" ទៅវិញ សម្រាប់ប្រជានុរាស្ត្រដែលរស់នៅជុំវិញប្រាសាទនោះ ដោយសារប្រាសាទទាំងនោះមានស្ថាបត្យកម្មរឹងមាំមួនល្អ, តាមថែវ, កំពែងយ៉ាងមាំ, តាមជ្រុងដែលអាចឲ្យប្រជានុរាស្ត្រមកជ្រកកោននៅទីនោះបានដោយគេជឿថា មានទេព, ទេវតា, ខ្មោចព្រាយបីសាចតាមជួយបិតបាំងរងមុខផង ។ ពុំនោះសោតទេ រហូតដល់ព្រះទៀតផង ដែលមានរឿងព្រេងប្រឌិតនៅចារជាប់ក្នុងសតិអារម្មណ៍គ្រប់ៗរូប ទោះជាពុំមានភាពច្បាស់លាស់ក៏ដោយ ។

ដូច្នេះ បើគេចង់ពន្យល់ "ពាក្យបន្ទាយ", (Banteay) ថា ហ្វកទៃរ៉េស្ស៍, ការហ្សែន៍ (Forteresse, Caserne) ដូចការពន្យល់ពាក្យ តាមបែបខ្មែរទំនើបនេះគឺ ជាការខុសឆ្គងដ៏ធ្ងន់, គឺន័យពុំបានគ្រប់គ្រាន់ល្អ និងពុំដែលមានឫសគល់នៃពាក្យស័ព្ទផង ដូចគេបានឃើញបន្តិចមកហើយ គឺជាអំពើបំផ្លាញនៃភាសាស័ព្ទ ដែលពុំស្គាល់បុព្វហេតុត្រឹមត្រូវ និងក្នុងផ្ទៃវប្បធម៌ជាតិផង [៣៤] ។

## ៨. ជំនឿ និងទេពកោសល្យរបស់អទី ឬ ជំនឿខ្មែរ

ព្រៃធំៗ, ឈើធំៗ, រូងភ្នំ, កំពូលភ្នំដែលខ្ពស់ៗ, ជ្រោះជ្រលងធំៗ, ក្នុងជំនឿខ្មែរតែងតែមាន : អ្នកតាភ្នំ, អ្នកតាព្រៃ, អារុក្ស-អារក្ស, ទេពរក្ស (ទេព+រក្ស=ទេព្រក្ស, ទេពារក្ស) និងព្រាយបីសាចសព្វគ្រប់នៅរក្សា និងចាំតទល់ជាមួយសត្រូវ [៣៥] ។ ធ្វើឲ្យមនុស្សព្រឺព្រួច, ញាប់ញ័រព្រោះតែជឿ ។ នៅពេលឆ្លង កាត់ទីកន្លែងអស់នេះ គេតែងបេះផ្កាថ្វាយដល់ព្រាយបីសាចទាំងនេះ ផ្សេងអំពីនោះទៀត គេគ្រវាសអង្ករ រួចគេបួងសួងសុំឲ្យបានប្រកបដោយសេចក្តីសុខសប្បាយសព្វប្រការ

34 [ពៅ សាវរស, មុខបាឋ: (ការសិក្សាផ្ទាល់ និងការសន្ទនាជាមួយគ្រូ), ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០០] ។

35 a. Ang, Chouléan, Les êtres surnaturels dans la religion populaire khmère, *Cedoreck*, 1986 ; b. Boulbet Jean, Pays de la Forêt, EFEO, t. CV, 1975 : 137… ; c. Forest, Alain, «Les cultes de génies protecteurs au Cambodge, Analyse et traduction d'un corpus de témoignages sur les Neak Tâ », *Editions L'Harmattan* 1992.

ក្នុងការធ្វើដំណើរ ទោះតាមជើងគោកក្តី តាមជើងទឹកក្តី (តាមមហាសមុទ្ទ) ។

មហានទីមេគង្គ ក៏ពុំផ្ញែកអំពីមហានទី "រ៉ាំង" (Rhin) ដែលតែងតែមានរឿងព្រេងនៅរស់រវើក ។ ចំពោះមតិខ្មែរវិញនោះ មហានទីមេគង្គជា "មហាទន្លេ" (Grand Fleuve, daule dhaṃ) ដែលមានទឹកធំល្វឹងល្វើយ រលកគគ្រាំគគ្រេង មានដំណើរបត់បែន, មានជ្រោំងចោទទ្រេង គួរបារម្ភគ្រប់ប្រការជាទូទៅ ពេលណាដែលគេធ្វើដំណើរតាមទូកនាវា គេតែងបន់ស្រន់គោរពទេព្តា, ព្រាយបីសាចទាំងនោះ ដែលហាក់ដូចជាព្រាយបីសាចទាំងនោះ តម្រូវឲ្យមនុស្សយកចិត្តទុកដាក់ដល់ពពួកគេ ឬ លើសពីនេះទៀត ឲ្យមនុស្សគោរពបូជាដល់ពពួកគេទៀតផង ។

ប្រសិនបើមហាគេហដ្ឋានមួយដែលគេលែងថែរក្សា, បោះបង់ចោលដោយចេតនា ឬអចេតនាគេហដ្ឋាននោះ ត្រូវក្លាយទៅជាទីស្នាក់នៅនៃខ្មោចព្រៃ ហើយក្លាយទៅជាគេហដ្ឋានដែលមានខ្មោចលងឥតល្ហកល្ហែ (តើរឿងនេះមិនគឺជារឿងក្នុងចិត្តសាស្ត្រទេឬ?) ។ គេហដ្ឋានខ្មោចលងនោះគេឃើញមានចំនួនច្រើនរយណាស់ក្នុងពិភពលោក ដែលមានប្រវត្តិនោះផ្តល់ឲ្យយើងរីករាយផងនិងផ្តល់ឲ្យយើងភ័យខ្លាចព្រឺរោមផង ។

កំណាព្យរឿងល្បើកអង្គរវត្តនេះ ត្រូវបានរៀបរៀងឡើងនៅដើមសតវត្សទី១៧ ដោយកវីប៉ាងតាត ដើម្បី "ស្ងូត្រ" សរសើរអំពីការស្ថាបនានៃប្រាសាទ ឬ ក្រុងមួយដ៏អស្ចារ្យ និងស្អាតល្អប្រណីតរកអ្វីផ្ទឹមពុំបានជាមួយប្រាសាទនោះ ។ ការនោះបានសេចក្តីថា : មេត្តាកុំភ័ន្តច្រឡំនិងស្នាដៃរបស់កវីទេពកោសល្យ និងសិល្បៈនិពន្ធរបស់គាត់ ដែលបានប្រឌិតរឿងល្បើកអង្គរវត្តនេះ ។

មានចលនាពីរយ៉ាងសំខាន់ដែលទាក់ទងនិងទំនៀម (វប្បធម៌) :

-ជំពូកទី១ កវីបានរំឭកយើងទាំងអស់អំពីរឿងព្រេង ដែលប្រជានុរាស្ត្រពាសពេញកម្ពុជាបានស្គាល់ច្បាស់ : គឺរឿងព្រេងដែលរំឭកឡើងអំពីបារមីរបស់ព្រះឥន្ទ្រ និងព្រះរាជបុត្រធម៌ (បុត្រពីជាតិមុន) ព្រះកេតុមាលាក្សត្រិយ៍ទីមួយនៅអង្គរដោយពគ្រាយខ្ញុំរខ្ចារនូវភាពល្បីល្បាញពាសពេញទាំងកម្ពុជា ។

-ជំពូកទី២ អ្នកនិពន្ធមានឧត្តមគតិក្នុងការគិតពិចារណាជ្រើសរើសរកបទ, ទុំនុកស្ងួតដ៏ល្អប្រពៃពីសម័យដើម ដែលរហូតដល់សព្វថ្ងៃ គេឥតបានស្គាល់ទំនុកស្ងួតរបៀបនេះទៀតទេ តាំងតែពីក្រោយការធ្លាក់ចុះនៃព្រះនគរមកនេះ ។

នេះដើម្បីនឹងឆ្លើយតបឲ្យត្រូវតាមការសោកសង្រេងគ្រប់ស្រទាប់ ប្រជារាស្ត្រដែលគ្មានអ្វីជាទី



ពឹង ជាទីពុំនាក់អាស្រ័យខាងវប្បធម៌ ។

អង្គរត្រូវសៀមខ្មោប, ស្រុតរលំនៅពាក់កណ្តាលសតវត្សទី១៥ហើយបន្ទាប់មកត្រូវព្រះមហាក្សត្រិយ៍បោះបង់ចោល ដោយផកទ័ពតាមយុទ្ធសាស្ត្រមកកាន់ភូមិភាគខាងត្បូងបន្តិចម្តងៗ ទីបំផុតមកនៅទិសខាងត្បូងតែម្តង ដោយសារតែសង្គ្រាម និងការឈ្លានពានដ៏សាហាវ ។

ព្រះមហានគរនេះ ពាក្យសំស្ក្រឹត និងខ្មែរចាស់ហៅថា "វ្រះមហានគរ" គឺនគរដ៏ធំខ្ពង់ខ្ពស់សម្រាប់សក្ការបូជា ។ ឈ្មោះនេះមានអត្ថន័យយ៉ាងធ្ងន់ ដែលគេហៅតាមសំនៀងរហូតដល់សព្វថ្ងៃថា "ព្រះនគរ" ឬ យ៉ាងខ្លី ថា "អង្គរ" (aṅgar) ដែលគេស្គាល់ទូទៅក្នុងសាកលលោក [៣៦] ។

នេះជានិមិត្តរូបជាទីសក្ការៈបូជា ស្ថិតនៅក្នុងបេះដូងប្រជានុរាស្ត្រខ្មែរ រហូតដល់ព្រះបូរីនេះត្រូវរំលំរលើង និងខ្មោចមហន្តរាយដែលជាបុព្វហេតុនៃវិបត្តិចិត្តសាស្ត្រយ៉ាងធ្ងន់យ៉ាងណា ក៏ប្រជារាស្ត្រខ្មែរនៅតែគោរពបូជាជាដ៏រាប ។

បន្ទាប់មកប្រជារាស្ត្រ ត្រូវរាជការ មន្ត្រីនៃរដ្ឋាភិបាលបោះបង់ចោល រស់នៅដោយរងទុក្ខវេទនា, អស់ថាមពល, ក្រខ្សត់, គ្មានធនធាន, គ្មានអំណាច, ទើបប្រជារាស្ត្រមួយចំនួនខ្លះស្វែងរកទ្រនុំ និងការទំនុកបំរុងវិញ ។ ខ្លះទៀតផ្ញើសេចក្តីសង្ឃឹមលើខ្មោចបិសាច, ពុំមែនដើម្បីកសាងបូរីឡើងវិញទេ តែដើម្បីស្វែងរកប្រភពដើមដ៏អស្ចារ្យរបស់គេវិញ តាមរយៈព្រះដ៏ធំគឺ "ព្រះឥន្ទ្រ" (Dieu Indra) និង ព្រះរាជាបុត្ររបស់ទ្រង់គឺ "ព្រះកេតុមាលា" (Braḥ Ketumālā) ។

រឿងព្រេងនេះ ក៏បានផ្សព្វផ្សាយពេញពាស និងយ៉ាងបន្ទាន់បំផុតដើម្បីចាប់ឫសបំបែកមែកធាងឡើងវិញ ក្នុងត្រកូលខ្មែរ និងអំបូរពូជធាងភាសាខ្មែរ ។ យើងខ្ញុំផ្ទាល់ពុំដែលបានដឹងថា : -បងប្អូនខ្មែរដើមរាប់លាននាក់ ដែលនៅតំបន់អតីតដែនដីខ្មែរខាងជើងជួរភ្នំដងរែក, -បងប្អូនខ្មែរដើមរាប់លាននាក់ដែលនៅតំបន់អតីតដែនដីខ្មែរនៅម្តុំភ្នំវត្តភូ, -និងម្យ៉ាងទៀត បងប្អូនខ្មែររាប់លាននាក់ទៀតដែរ ដែលនៅតំបន់ដែនដីសណ្តរនៃទន្លេមេគង្គ ថាគាត់ចេះចាំរឿងល្បើកអង្គរវត្តឬទេ ។ ប៉ុន្តែ នៅក្នុងដែនដីនៃប្រទេសកម្ពុជាសព្វថ្ងៃវិញ រឿងព្រេងនេះបានចាក់ឫសយ៉ាងជ្រៅមាំជាពិសេសក្នុងការដំណាលបន្តៗគ្នាពីជីតាទៅចៅ ។ តើមានរូបជនខ្មែរណាម្នាក់ដែលពុំបានដឹងរឿងព្រេងនេះ រឿងនេះត្រូវព្រះសង្ឃលោកយកមកបង្រៀននៅក្នុងវត្ត ដល់យុវសង្ឃ (យុវសាមណេរ) ដែលពុះពោរកញ្ច្រោលដោយចំណង់សិក្សាយកចំណេះ ដែលប្រាកដហើយថា ក្នុងចំណោមយុវ-

36. Voir Pou, Saveros, op.cit. *BEFEO*, t. LXXVIII, 1991 : 203...

សង្ឃទាំងនោះ មានយុវសង្ឃមួយព្រះអង្គ ព្រះនាមជាំង ឆាត នេះដែរ...។

### ៩. យោបល់ និង ឧស្សាហៈបញ្ចប់

**ទោះ**ជាប្រទេសកម្ពុជាឈានចូលដល់សម័យទំនើប និងចូលក្នុងសតវត្សទី២០ក្តី ក្នុងក្រោងទ្វារពិភពឧស្សាហកម្មទំនើបក្តី ហើយខ្វល់ខ្វាយតែស្វែងរកលាភសក្ការៈ ជាសម្ភារៈក្តី ព្រះកេតុមាលាស្ថិតនៅជាមួយប្រជានុរាស្ត្រទាំងអស់ជានិច្ច ហើយព្រះនាមនេះត្រូវបានខ្មែរយកទៅដាក់ ឲ្យមន្ទីរពេទ្យមួយនៅទីក្រុងភ្នំពេញ ដោយប្រសិទ្ធិនាមថា **"មន្ទីរពេទ្យព្រះកេតុមាលា"** ។

បើតាមយើងខ្ញុំយល់ម្យ៉ាងទៀតថា អ្នកនិពន្ធជាំង ឆាត ពុំមែនមានគំនិតគ្រាន់តែសរសើរ មហាបុព្វបុរសយើងតែម្នាក់លោកប៉ុណ្ណោះទេ ប៉ុន្តែ លោកបានទាំងណែនាំប្រជារាស្ត្រ និងក្សត្រិយ៍ខ្មែរពីស.វ.ទី១៦ ដល់ដើម ស.វ.ទី២០នេះ ឬទាំង២១ផង ឲ្យចេះគោរពបូជាបុរីអង្គរ ព្រះមហានគរ (ឥន្ទ្រប្រស្ថបុរី) គោរពបូជាអតីតព្រះមហាក្សត្រិយ៍ខ្មែរ, អតីតវិស្វករខ្មែរ, អតីតប្រជារាស្ត្រខ្មែរដែលជាអ្នកទទួលថែរក្សាមត៌កជាតិ, សម្បត្តិវប្បធម៌ដ៏ពិសេសពិសាលរបស់សាសន៍យើងនេះ ឲ្យបានខ្ពង់ខ្ពស់ស័ក្តិសមព្រះកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់មហាបុព្វបុរសទាំងនេះផងដែរ ទើបបានជាលោកកវី-និពន្ធជាំង ឆាត គាត់តែង, ចារចែង, ចងក្រងនូវរឿង "ល្បើកអង្គរវត្ត" នេះទុកតមកជាកេរ្តិ៍គល់ បន្តដល់ជំនាន់យើង និងកូនចៅជំនាន់ក្រោយៗរហូតទៅ ។

ដូច្នេះ ព្រះមហាក្សត្រិយ៍ និងប្រជារាស្ត្រខ្មែរទេ ដែលជាអ្នកទទួលមត៌កអង្គរពីបុព្វបុរសខ្មែរនោះមេត្តានាំគ្នា គិតគូរជួយការពារថែរក្សា និងលើកតម្លៃកេរ្តិ៍មត៌កដ៏ប្រពៃនេះ ឲ្យបានមាំមួនដោយខ្លួនឯង កុំសង្ឃឹមតែទៅលើ "អង្គការវប្បធម៌ពិភពលោក" (យូណេស្កូ) ទាំងស្រុងពេក ៕



## កំណត់ឯកសារ


១. ជាភាសាខ្មែរ :

- វចនានុក្រមខ្មែរ ភាគទី១ បោះពុម្ពដោយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៧ ។
- វចនានុក្រមខ្មែរ ភាគទី២ បោះពុម្ពដោយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៨ ។
- ឃួន សុខម្ភ អ្នក ប៉ង ល្បើកអង្គរវត្ត មណ្ឌលរកឯកសារ និងស្រាវជ្រាវផ្នែកអក្សរសាស្ត្រ-វប្បធម៌អរិយធម៌ខ្មែរ មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ ភ្នំពេញ គ.ស.១៩៧១ ។
- ល្បើកអង្គរវត្ត ចុះផ្សាយក្នុង ប្រក្រតិទិន ឆ្នាំឆ្លូវ បញ្ចស័ក ព.ស.២៥១៧ គ.ស.១៩៧៣ ទំព័រទី២៥ ដល់ ៧៩ ។

ពៅ សាវរស

1979. a Rāmakerti I, (Texte Khmer XVI-XVII ème siècle), *P.E.F.E.O.*

1982. b Rāmakerti II, (Texte Khmer XVI-XVII ème siècle), *P.E.F.E.O.*

២. ជាភាសាបរទេស (បារាំង)

George Coedès

1911. a «Les Bas-Relifs d'Angkor Vatt», *B.C.A.I.*

1962. b «La date d'exécution des deux Bas-Reliefs tardifs d'Angkor Vatt», *Journal Asiatique*, t. CCL.

Jean Przyluski,

1923 «La Légende de Rāma dans les Bas-Reliefs d'Angkor Vatt», *A.A.K.*

George Coedès, Louis Finot, Victor Goloubew,

1932 Temple d'Angkor Vatt, Mémoires Archélogiques, 3 Volumes, Paris *P.E.F.E.O.*

Madeleine Giteau,
1969. a «A propos d'un épisode de Rāmakerti représente à Vatt Pūpī » (Siem Rāp), *Arts Asiatiques*, XIX.
1975. b Iconographie du Cambodge Post-Angkorien, Volume C, Paris *P.E.F.E.O.*

Saveros Pou,
1971. a «Inscriptions Modernes d'Angkor Vatt» , (I.M.A), *B.E.F.E.O*, t. LVIII.
1972. b «I.M.A.», *B.E.F.E.O*, t. LIX.
1972. c «I.M.A.», *Journal Asiatique.*
1973. d «I.M.A.», *B.E.F.E.O*, t. LX.
1975. e Notes sur la date du Poème d'Angkor Vatt, *Journal Asiatique.*
1988. f Kamraṅ Cpāp', Guilande de Cpāp', 2 Volumes, Paris Cedoreck.
2001. g Nouvelles Inscriptions du Cambodge (N.I.C.), t. II et III, *P.E.F.E.O.*
2004. h Dictionnaire Vieux Khmer-Français-Anglais, An Old Khmer-French-English Dictionary (2ème Edition), *Editions L'Harmattan*, Paris (Les introuvables).

Saveros Pou et Grégory Mikaelian
2007 Rāmakerti I, «La Gloire de Rāma», Drame épique médiéval du Cambodge, *L'Harmattan,* Paris (Les introuvables).

